NUM
2024

**ក្រសួងអប់រំ យុវជន និងកីឡា**
**សាកលវិទ្យាល័យជាតិគ្រប់គ្រង**
**សាលាក្រោយបរិញ្ញាបត្រ**

# ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នៅលើការលើកកម្ពស់ ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព

**ហ្គេក លក្ខណា**

និក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**ជំនាញ គ្រប់គ្រងពាណិជ្ជកម្ម**

**ភ្នំពេញ**
ឆ្នាំ ២០២៤

# ក្រសួងអប់រំ យុវជន និងកីឡា
## សាកលវិទ្យាល័យជាតិគ្រប់គ្រង
## សាលាក្រោយបរិញ្ញាបត្រ

# ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅលើការលើកកម្ពស់ ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព

**ហ្តេក លក្ខណា**

និក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌប្រឡងបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**ជំនាញគ្រប់គ្រងពាណិជ្ជកម្ម**

**ភ្នំពេញ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**សាកលវិទ្យាល័យជាតិគ្រប់គ្រង**

**សាលាក្រោយបរិញ្ញាបត្រ**


# ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព


**ហ្កេក លក្ខណា**


និក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
ជំនាញគ្រប់គ្រងពាណិជ្ជកម្ម


**សាស្ត្រាចារ្យណែនាំ**

**បណ្ឌិត ហេង សុភាព**



**ភ្នំពេញ**

ឆ្នាំ ២០២៤

# អំណះអំណាង

នាងខ្ញុំឈ្មោះ **ហ្គេក លក្ខណា** អក្សរឡាតាំងGAK LEAKHNA កើតថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០០ ទីកន្លែងកំណើត ភូមិឫស្សីជ្រោយ ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្ដាល។ បច្ចុប្បន្នជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ជំនាន់២៥ ក្រុមM04 ឆ្នាំសិក្សា២០២២-២០២៤។

នាងខ្ញុំសូមធានា និងទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារក្នុងរបាយការណ៍នេះគឺជាស្នាដៃស្រាវជ្រាវរបស់នាងខ្ញុំផ្ទាល់មិនមានពាក់ព័ន្ធជាមួយរបាយការណ៍ ឬនិក្ខេបបទរបស់អ្នកផ្សេងៗឡើយដោយគ្រាន់តែដកស្រង់នូវចំណុចគោលៗមួយចំនួនពីឯកសារចាស់ៗ ដែលធ្លាប់មានសរសេរកន្លងមកប៉ុណ្ណោះមិនមានចម្លងទាំងស្រុងឡើយ។ ទិន្នន័យនិងលទ្ធផលដែលទទួលបាននៃការសិក្សាស្រាវជ្រាវដែលបានលើកឡើងក្នុងអត្ថបទនេះគឺជាអត្ថបទថ្មីហើយគ្មានជនណាមួយយកទៅប្រើប្រាស់ក្នុងរបាយការណ៍ឬនិក្ខេបបទរបស់គេនោះឡើយ។



**ហ្គេក លក្ខណា**

សាកលវិទ្យាល័យជាតិគ្រប់គ្រង

រាជធានីភ្នំពេញ,ប្រទេសកម្ពុជា

ថ្ងៃសៅរ៍ ៣រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧

ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ហ្គេក លក្ខណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ជំនាន់២៥ ក្រុមM0៤ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នាងខ្ញុំសូមគោរពអរគុណ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំង៣រួមមានអ្នកម្ដាយសោភា អ្នកម្ដាយសុខា លោកឪពុកសារិទ្ធ ដែលលោកបានផ្ដល់កំណើត ផ្ដល់ការចិញ្ចឹមបីបាច់ថែរក្សា ការអប់រំ ការផ្ដល់ដំបូន្មាន ព្រមទាំងការលើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យកូនបានទទួលនូវការការសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវចំណេះដឹង ចំណេះធ្វើ និងរស់នៅដោយសេចក្ដីថ្លៃថ្នូរ មានការព្យាយាមអធ្យាស្រ័យ និងមានសីលធម៌ល្អក្នុងការរស់នៅព្រមទាំងសូមថ្លែងអំណរគុណដល់បងប្រុស បងស្រីដែលលោកតែងតែផ្ដល់ក្ដីស្រលាញ់ និងការជំរុញបន្ថែមចំពោះប្អូន។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បុគ្គលិក នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងដែលបានខិតខំបង្ហាត់បង្ហាញ ផ្ដល់ការណែនាំ ការតម្រង់ទិសយ៉ាងយកចិត្តទុកដាក់ និងនូវទស្សនទានល្អៗសម្រាប់ជាប្រយោជន៍ក្នុងការអភិវឌ្ឍសមត្ថភាពរបស់នាងខ្ញុំ។ ព្រមជាមួយនេះ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **ហេង សុភាព** ដែលលោកបានចំណាយនូវពេលវេលាដល់មានតម្លៃក្នុងការណែនាំ ដឹកនាំ ផ្ដល់ដំបូន្មាន ការប្រឹក្សាយោបល់ ការត្រួតពិនិត្យ និងកែលម្អនូវចំណុចខ្វះចន្លោះក្នុងដំណើរការនៃការសរសេរកិច្ចការស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះចាប់តាំងពីពេលចាប់ផ្ដើមរហូតដល់ចប់។

ជាមួយគ្នានេះដែរ នាងខ្ញុំសូមថ្លែងអំណរអរគុណជាពិសេសចំពោះថ្នាក់ដឹកនាំ និងបុគ្គលិក នៃគណៈកម្មាធិការជាតិអូឡាំពិក អគ្គនាយកដ្ឋានកីឡា ព្រមទាំងស្ថាប័នពាក់ព័ន្ធ ដែលបានផ្ដល់ឱកាសដល់រូបនាងខ្ញុំទទួលបាននូវចំណេះដឹងថ្មីៗ និងជំនាញក្នុងការបន្តការអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធិផលខ្ពស់បន្ថែមទៀត។

ជាចុងក្រោយ នាងខ្ញុំសូមគោរពជូនពរសព្វសាធុការ ជូនចំពោះសាស្ត្រាចារ្យដឹកនាំកិច្ចការស្រាវជ្រាវ ថ្នាក់ដឹកនាំបុគ្គលិក នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងព្រមទាំងថ្នាក់ដឹកនាំ និងបុគ្គលិក នៃគណៈកម្មាធិការជាតិអូឡាំពិក អគ្គនាយកដ្ឋានកីឡា ស្ថាប័នពាក់ព័ន្ធ ទាំងអស់សូមសមប្រកបតែពុទ្ធពរទាំងឡាយទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយនិងសូមរកទទួលទានមានបានប្រាថ្នាអ្វីសូមឱ្យបានសម្រេចជោគជ័យដូចបំណងប្រាថ្នា។

# សេចក្តីសង្ខេប


តាមរយៈការសិក្សាស្រាវជ្រាវបានបញ្ជាក់ឱ្យឃើញថាការចូលរួមជំរុញ និងផ្តោតរបស់រាជរដ្ឋាភិបាលខ្លាំង នៅលើវិស័យកីឡាក៏អាចជាកត្តាភ័នច្រឡំចំពោះទស្សនៈនៃការយល់ឃើញអំពីការចំណាយច្រើនទៅលើការ រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការចំណាយធនធានរបស់រាជរដ្ឋា-ភិបាលដោយភាគច្រើនកើតឡើងដោយភាពកង្វះខាតនូវការទទួលបានពត៌មាននិងការយល់ដឹងលម្អិតពីសារៈសំខាន់ដែលទាក់ទងនិងទស្សនវិស័យនៃការដឹកនាំនិងគោលដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ ការកើនឡើងនៃការភ័នច្រឡំជាកត្តាជះឥទ្ធិពលយ៉ាងសំខាន់ដែលរារាំងយ៉ាងខ្លាំងក្នុងការអនុវត្តការងារលើវិស័យនេះ។

ការសិក្សាការលើកកម្ពស់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីផ្សារកីឡានៅខណ្ឌជ្រោយ-ចង្វារ ជាការពិចារណាយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសហគមន៍ និងអភិវឌ្ឍវិស័យសេដ្ឋកិច្ច។ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺជាការសាងសង់ ជួសជុល កែលម្អ និងថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំកាយតាមគ្រឹះស្ថានសិក្សា ព្រមទាំងនៅក្នុងសហគមន៍។ ទីផ្សារកីឡាគឺជាសំដៅដល់ការទិញ ឬលក់សម្ភារៈកីឡា ផលិតផលបរិក្ខារកីឡា សំបុត្រ ទស្សនា ចំណីអាហារកីឡា ភេសជ្ជៈកីឡា ទស្សនីយភាពកីឡា ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ការផ្សាយពាណិជ្ជកម្ម ធានារ៉ាប់រង សេវាសុខភាពអ្នកឧបត្ថម្ភគាំទ្រ ការដោះដូរ ការទិញឬលក់កីឡាករពីក្លឹបមួយទៅក្លឹបមួយ។ សរុបមកផល-ប្រយោជន៍ខាងលើនេះពិតជាបានជួយរំលឹកដល់អ្នកធ្វើផែនការ និងអ្នកសិក្សាស្រាវជ្រាវដែលសិក្សាពាក់ព័ន្ធស្វែងយល់អំពីសារៈសំខាន់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីផ្សារកីឡា រួមទាំងការរួមចំណែកដល់សកម្មភាពសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ។ ដូច្នេះក្នុងបរិបទនេះដោយសារការសិក្សារបស់ប្រជាពលរដ្ឋក្នុងនៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ក៏ដូចជាអ្នករៀបចំផែនការ និងអ្នកសិក្សាស្រាវជ្រាវឱ្យសមស្របមួយសម្រាប់ការអភិវឌ្ឍសហគមន៍ខណ្ឌជ្រោយចង្វារផងដែរ។

ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពជាកត្តាដ៏ចម្បងនិងមានសារៈសំខាន់បំផុតក្នុងការជួយជំរុញនិងបំពេញបន្ថែមនូវរាល់ភាពចាំបាច់និងតម្រូវការក្នុងសកម្មភាពចូលរួមចំណែករបស់ វិស័យកីឡាក្នុងន័យដើម្បីធានាឱ្យបាននិរន្តរ៍ភាពនិងការចូលរួមយ៉ាងសកម្មភាពនិងសំខាន់ក្នុងផ្នែកមួយនៃការលើកកម្ពស់ការអភិវឌ្ឍសហគមន៍។

# មាតិកា

## ចំណងជើង


អំណោះអំណាង....................................................................................................... i

សេចក្តីថ្លែងអំណរគុណ............................................................................................. ii

សេចក្តីថ្លែងសង្ខេប................................................................................................. iii

**ជំពូកទី១៖ សេចក្តីផ្តើម ............................................................................... ១**

១.១- សារតានៃការសិក្សាស្រាវជ្រាវ......................................................................... ១

១.២- ការថ្លែងបញ្ហា.................................................................................................. ២

១.៣- សំណួរស្រាវជ្រាវ............................................................................................. ២

១.៤. គោលបំណងនៃការសិក្សារស្រាវជ្រាវ................................................................ ៣

១.៥. ការតាងសម្មតិកម្ម.......................................................................................... ៣

១.៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ.................................................................. ៣

១.៧. ទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ......................................................... ៤

១.៨. គម្រោងក្នុងកាសិក្សាស្រាវជ្រាវ......................................................................... ៥

**ជំពូកទី២៖ រំលឹកទ្រឹស្តី..................................................................................... ៨**

២.១. និយមន័យ ឬពាក្យគន្លឹះ.................................................................................. ៨

២.២. ការចូលរួមរបស់វិស័យកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៅក្នុងសហគមន៍..១០

២.២.១.ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព...... ១១

២.២.២.ហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព............... ១២

២.២.៣.ភាសាសកលនៃវិស័យកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព......... ១៣

២.២.៤.ទីផ្សាកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព................................ ១៤

២.៣. ការរំលឹកឡើងវិញនៃវិធីសាស្ត្រស្រាវជ្រាវ........................................................ ១៦

២.៤. គោលគំណិតនៃការស្រាវជ្រាវ........................................................................ ១៧

២.៥. ក្នុងករណីខណ្ឌជ្រោយចង្វារតម្រូវការស្រាវជ្រាវ............................................. ១៨

២.៥.១.ស្ថានភាពទូទៅ............................................................................................ ១៨

២.៥.២.ក្របខណ្ឌសេដ្ឋកិច្ចសង្គម និងចំនួនប្រជាពលរដ្ឋ.............................................. ១៩

២.៥.៣.មុខរបរភាគច្រើន......................................................................................... ១៩

២.៥.៤.អភិវឌ្ឍខណ្ឌឆ្លាតវៃ ចីរភាព និងបរិយាបន្ន......................................................... ១៩

២.៦. ការសន្និដ្ឋាន................................................................................................. ២០

**ជំពូកទី៣៖វិធីសាស្ត្រក្នុងការស្រាវជ្រាវ** ........ **២១**
៣.១. ប្រភេទនៃការវិភាគទិន្នន័យ ........ ២១
៣.២. ទំហំ និងបច្ចេកទេសនៃការជ្រើសរើសទិន្នន័យ ........ ២២
៣.៣. ប្រភពទន្និន័យ ........ ២៣
៣.៤. ឧបករណ៍វិភាគទិន្នន័យ ........ ២៣
៣.៥. វិធីសាស្ត្រនៃការវិភាគទិន្នន័យ ........ ២៤
៣.៦. សេចក្តីសន្និដ្ឋាន ........ ២៤

**ជំពូកទី៤៖វិធីសាស្ត្រក្នុងការស្រាវជ្រាវ** ........ **២៦**
៤.១. សេចក្តីផ្តើម ........ ២៦
៤.២. ភាពជឿជាក់នៃឧបករណ៍ការស្រាវជ្រាវ ........ ២៦
៤.៣. ការវិភាគទិន្នន័យ ........ ២៧
៤.២.១. ពត៌មានទូទៅរបស់អ្នកផ្តល់ទិន្នន័យ ........ ២៨
៤.២.១.១. ភេទរបស់អ្នកផ្តល់បទសម្ភាសន៍ ........ ២៨
៤.២.១.២. អាយុរបស់អ្នកផ្តល់បទសម្ភាសន៍ ........ ២៨
៤.២.១.៣. កម្រិតសិក្សារបស់អ្នកផ្តល់បទសម្ភាសន៍ ........ ២៩
៤.២.១.៤. មុខរបរបច្ចុប្បន្នរបស់អ្នកផ្តល់បទសម្ភាសន៍ ........ ២៩
៤.២.១.៥. អាស័យដ្ឋានរបស់អ្នកផ្តល់បទសម្ភាសន៍ ........ ៣០
៤.៣. ការវាយតម្លៃប្រសិទ្ធភាព ........ ៣០
៤.៤. ការវាយតម្លៃលទ្ធផលនៃការស្រាវជ្រាវ ........ ៣១
៤.៤.១. ការបកស្រាយ Multicollinearity ........ ៣១
៤.២.២. ការតេស្តNormal Distribution ........ ៣២
៤.២.៣. Homoscedasticity Check ........ ៣៣

**ជំពូកទី៥៖លទ្ធផលនិងការពិភាក្សា** ........ **៣៥**
៥.១. សាវតា ........ ៣៥
៥.២. អត្ថប្រយោជន៍និងការអនុវត្តល្អរបស់វិស័យកីឡា ........ ៣៦
៥.២.១. ការអនុវត្តន៍ល្អរបស់កម្ពុជាចំពោះវិស័យកីឡា ........ ៣៦
៥.២.២. យុទ្ធសាស្ត្របញ្ហាកោណរបស់រាជរដ្ឋាភិបាល ........ ៤០
៥.៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីធ្លាបៃតងសាធារណៈ សម្រាប់លើកកម្ពស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ ........ ៤០
៥.៣.១. ហេដ្ឋារចនាសម្ព័ន្ធ ........ ៤០
៥.៣.២. ទីធ្លាបៃតងសាធារណៈ ........ ៤០
៥.៤. សន្និដ្ឋាន ........ ៤១

**ជំពូកទី៦៖សេក្តីសន្និដ្ឋាននិងអនុសាសន៍**........................................................... **៤៣**
៦.១. សេចក្តីសង្ខេប........................................................................................ ៤៣
៦.២. សេចក្តីសន្និដ្ឋាន.................................................................................... ៤៣
៦.៣. លទ្ធផលនិងអនុសាសន៍............................................................................ ៤៤
៦.៤. ដែនកំណត់និងការស្រាវជ្រាវនាពេលអនាគត.................................................... ៤៤
ឯកសារយោង.................................................................................................. ៤៦
ឧបសម្ព័ន្ធ...................................................................................................... ៤៩

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១.សាវតានៃការសិក្សាស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាយកចិត្តទុកដាក់ដល់វិស័យអប់រំកាយនិងកីឡា សំដៅលើកកម្ពស់សុខភាពនិងសុខុមាលភាពរបស់ប្រជាជនគ្រប់រូប។ ជាការពិតណាស់ វប្បធម៌នៃកីឡាកំពុងតែមានភាពពាក់ព័ន្ធ និងសំខាន់មិនត្រឹមតែនៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកាន់កាប់កន្លែងពិសេសមួយ ដែលជាសាខាដាច់ដោយឡែកនៃសេដ្ឋកិច្ចរបស់ប្រទេសផងដែរ។ បរិយាកាសម៉ាក្រូសេដ្ឋកិច្ចត្រូវបានផ្លាស់ប្តូរយ៉ាងខ្លាំង ទំនាក់ទំនងអចលនទ្រព្យនៅក្នុងប្រព័ន្ធនៃអង្គការកីឡា និងហេដ្ឋារចនាសម្ព័ន្ធរបស់ពួកគេត្រូវបានផ្លាស់ប្តូរប្រកប ដោយគុណភាព ហើយសកម្មភាពរបស់ក្លឹប និងសហព័ន្ធកីឡាជាច្រើនត្រូវបានដាក់នៅលើមូលដ្ឋានទីផ្សារ។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលរៀបចំឱ្យមានបរិស្ថាន ល្អ ខ្យល់អាកាសបរិសុទ្ធ មានឧទ្យានបៃតង និងទីធ្លាសម្រាប់លំហាត់ប្រាណ និងកីឡា ដើម្បីទ្រទ្រង់សុខភាពនិងសុខុមាភាពប្រជាជនទាំងផ្លូវកាយទាំងផ្លូវចិត្ត (អយក. ឆ្នាំ២០១៥)។

ជាក់ស្តែងប្រទេសកម្ពុជានាពេលកន្លងមកបានធ្វើការកែទម្រង់គ្រប់មធ្យោបាយក្នុងអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ក្នុងទីជនបទ និងតាមបណ្តាលសហគមន៍នានាឱ្យមានការរីកចម្រើនដើម្បីជួយជម្រុញដល់កម្រិតជីវភាពរស់នៅ។ ដោយឃើញពីការរីកចម្រើននៃវិស័យកីឡាក្នុងប្រទេសកម្ពុជា និងដោយសង្កេតឃើញពីការចូលរួមយ៉ាងសកម្មក្នុងការជួយពន្លឿនសកម្មភាពចូលរួមចំណែកអភិវឌ្ឍសក្តានុពលប្រទេសជាតិបន្ថែមពីនេះទៅទៀត វិស័យកីឡាជាវិស័យដែល **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា** បានថ្លែងថា វិស័យកីឡាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានដើរតួនាទីយ៉ាងសំខាន់ ទាំងនៅកម្ពុជា និង សកលលោក, ដោយកីឡាទទួលបាននូវការចាប់អារម្មណ៍ និង គាំទ្រកាន់តែច្រើនពីសំណាក់មហាជន គ្រប់ស្រទាប់វណ្ណៈ ដោយមិនគិតពីពណ៌សម្បុរ ឬ និន្នាការនយោបាយឡើយ (Press OCM ប្រសាសន៍ របស់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីក្នុងឱកាសសម្តេចចូលរួមនៅក្នុងពិធីបើកផ្លូវការ«ការប្រកួតគុនចម្រុះជ្រើសរើសជើងឯកអាស៊ីលើកទី២»)។ ក្នុងន័យនេះ ព្រឹត្តិការណ៍កីឡាមិនមែនគ្រាន់តែជាការប្រកួតមួយប៉ុណ្ណោះទេ, ប៉ុន្តែជាងនេះទៀត ព្រឹត្តិការណ៍ប្រកួតកីឡា គឺជាឱកាសសម្រាប់ផ្សព្វផ្សាយទេសចរណ៍ វប្បធម៌ សង្គម សេដ្ឋកិច្ច និង កេរ្តិ៍ឈ្មោះប្រទេសជាតិ, ក៏ដូចជារួមចំណែកដល់ការពង្រឹងចំណងសាមគ្គីភាព និង មិត្តភាព រវាងប្រតិភូកីឡានៃប្រទេសដែលបានចូលរួម(Chivorn, 2024)។

ជាការពិតណាស់ក្រោមការដឹកនាំដោយឆ្លាតវៃរបស់រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយទៅដោយរីកចម្រើនគ្រប់វិស័យ។ ជាមួយគ្នានេះផងដែរ តំបន់ជ្រោយចង្វារគឺពិតជាមានសក្តានុពលខ្លាំងទៅលើសេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជាទាំងមូល បានន័យថាទីក្រុងរណបជ្រោយចង្វារនឹងក្លាយជាទីក្រុងមួយប្រកបទៅដោយភាពរីករាយ និងរីកចម្រើលើគ្រប់វិស័យដោយប្រណីតភាព និងការរីកចម្រើនលូតលាស់ផ្សេងៗដែលកើតចេញពីទំនើបកម្មនៃការអភិវឌ្ឍនាពេលបច្ចុប្បន្ន។ មិនត្រឹមតែប៉ុណ្ណោះការរៀបចំទីក្រុងរណបជ្រោយចង្វារ

គឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែមានភាពរីកចម្រើនឡើង ព្រោះដោយហេតុថាទីក្រុងណាបមួយនេះនឹងក្លាយជាគោលដៅសេដ្ឋកិច្ចសម្រាប់វិនិយោគធំៗជាច្រើនមិនឡើង ព្រោះដោយហេតុថាទីក្រុងណាបមួយនេះនឹងក្លាយជាគោលដៅសេដ្ឋកិច្ចសម្រាប់វិនិយោគធំៗជាច្រើនមិនថាផ្នែកសំណង់ អគារ ការរស់នៅ ក៏ដូចជាការកំសាន្ត ទេសចរណ៍ជាដើម ជាមួយនឹងទីតាំងតំបន់ដែលអំណោយផលយ៉ាងខ្លាំង។

## ១.២. ការថ្លែងបញ្ហា

ក្នុងពេលបច្ចុប្បន្ននេះ រាជរដ្ឋាបាលកម្ពុជាបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ ក៏ដូចជាបង្កើតឱកាសឱ្យមានការចូលរួមជាសកម្មភាព ដើម្បីរិះរកគ្រប់មធ្យោបាយក្នុងការដោះស្រាយរាល់បញ្ហាដែលកើតមានឡើង និងធ្វើយ៉ាងណាឱ្យសុខុមាលភាពសហគមន៍(សេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌)វិវត្តន៍ចេញពីសកម្មភាពរួមដែលត្រូវបានអនុវត្តនៅកម្រិតមូលដ្ឋានស្របជាមួយគំនិតផ្តួចផ្តើមតូចៗនៅក្នុងក្រុមហូតដល់គំនិតផ្តួចផ្តើមធំៗដែលពាក់ព័ន្ធនឹងសហគមន៍ផ្ទាល់។ ទោះជាយ៉ាងណាការលើកកម្ពស់ទីធ្លាសាធារណៈបៃតង និងសុខុមាលភាពនៅក្នុងសហគមន៍នីមួយៗនៅមានកម្រិត និងបញ្ហាប្រឈម ដោយសារតែមានដំណើរវិវត្តឥតឈប់ឈរសម្រាប់ការអភិវឌ្ឍប្រទេសពីមួយទស្សវត្សរ៍ ទៅមួយទស្សវត្សបាននាំមកនូវការផ្លាស់ប្តូរយ៉ាងខ្លាំងក្លា និងឆាប់រហ័សបំផុតបែបផែនសម្រាប់ការរស់នៅ ក៏ដូចជាបរិបទនៃការរស់នៅរបស់មនុស្សទីមួយជំនាន់ទៅមួយជំនាន់។ ដំណើរវិវត្តនេះបាននាំមកនូវភាពជឿនលឿនល្អប្រសើរ ក៏ដូចជាផ្តល់នូវភាពងាយស្រួលដែលអាចបម្រើទៅដល់ការរស់នៅរបស់មនុស្សជាតិ និងធ្វើឱកយមានគុណភាពនៃការរស់នៅ។ ទន្ទឹមនឹងវឌ្ឍនៈភាពនេះ វាក៏បានចោទជាបញ្ហារាប់រយរាប់ពាន់ជំពូកដែលអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងរដ្ឋត្រូវតែដោះស្រាយឱ្យខានតែបាន ទៅលើការអភិវឌ្ឍយ៉ាងសស្រាក់សស្រាំ ជាពិសេសលើការវិនិយោគដូចជាសំណង់អគារធំៗជាច្រើនដូចជា ខុនដូ អគារពាណិជ្ជកម្ម ផ្សារទំនើប កន្លែងកំសាន្ត ទីធ្លាសួនច្បារជាច្រើនបានកើនឡើង និងរីករាលសាលដូចផ្សិត (ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តភាពសម្រាប់រាជធានីក្រុងភ្នំពេញ ២០១៨-២០៣០)។

## ១.៣.សំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងឆ្លើយសំណួរស្រាវជ្រាវសំខាន់ៗចំនួនបីដូចខាងក្រោម៖

- តើអ្វីជាការចូលរួមរបស់វិស័យកីឡានៅក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ?
- តើកត្តាអ្វីខ្លះដែលជំរុញឱ្យមានការចូលរួមពីសហគមន៍របស់សិស្ស និស្សិត យុវជន ប្រជាពលរដ្ឋលើទស្សនៈនៃការយល់ឃើញពីគុណប្រយោជន៍ និងគុណវិបត្តិ លើវិស័យកីឡា?
- តើការចូលរួមរបស់វិស័យកីឡាទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញដែរឬទេ ?

## ១.៤.គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនេះ គឺមាន៖

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាទៅតាមទីធ្លាបៃតងសាធារណៈក្នុងការអភិវឌ្ឍសហគមន៍ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
- កែលម្អ និងអនុវត្តកម្មវិធីដើម្បីជំរុញទឹកចិត្តប្រជាជនម្នាក់ឱ្យលេងកីឡាយ៉ាងហោចណាស់មួយសម្រាប់ជីវិត ទៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនគ្រប់រូបនៅក្នុងការអភិវឌ្ឍសហគមន៍
- លើកកម្ពស់ទីផ្សារកីឡា ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានចំណេះដឹងពីភាសាសកលនៃវិស័យកីឡា
- ទាញសេចក្ដីសន្និដ្ឋាន និអនុសាសន៍

## ១.៥.ការតាងសម្មតិកម្ម

នៅក្នុងការសិក្សាស្រាវជ្រាវមួយយើងត្រូវបែងចែងឱ្យដាច់រវាងអថេរពីរគឺ អថេរឯករាជ្យ អថេរពឹងផ្អែក។ ដោយអថេរទាំង២នេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវ និងអាចនាំឱ្យការសិក្សាស្រាវជ្រាវមានភាពច្បាស់លាស់ជាងមុន និងងាយស្រួលក្នុងការប្រមូលឯកសារ និងទិន្នន័យជាពិសេសការរៀបចំកម្រងសំណួរនៃប្រធានបទនីមួយៗ។ នៅក្នុងការតាងរបស់អថេរឯករាជ្យ និងអថេរពឹងផ្អែក បានធ្វើឱ្យយើងអាចទាញបាននូវសម្មតិកម្មសំខាន់ៗចំនួន០៤រួមមាន៖

**សម្មតិកម្មសូន្យទី១(Ho1)៖ការយល់ដឹងរបស់ប្រជាពលរដ្ឋ** មិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

**សម្មតិកម្មសូន្យទី២(Ho2)៖ ហេដ្ឋារចនាសម្ព័ន្ធកីឡា** មិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

**សម្មតិកម្មសូន្យទី៣(Ho3)៖ ភាសាសកលនៃវិស័យកីឡា** មិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

**សម្មតិកម្មសូន្យទី៤(Ho4)៖ ទីផ្សារកីឡា** មិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

## ១.៦.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពជាកត្តាដ៏ចម្បងនិងមានសារៈសំខាន់បំផុតក្នុងការជួយជំរុញនិងបំពេញបន្ថែមនូវរាល់ភាពចាំបាច់និងតម្រូវការក្នុងសកម្មភាពចូលរួមចំណែករបស់ វិស័យកីឡាក្នុងន័យដើម្បី

ជានាឱ្យបាននិរន្តរភាពនិងការចូលរួមយ៉ាងសកម្មភាពនិងសំខាន់ក្នុងផ្នែកមួយនៃការលើកកម្ពស់ការអភិវឌ្ឍជីវភាពសហគមន៍។ ហើយការភាពសកម្មនិងសក្តានុពលនៃភាពខ្លាំងរបស់វិស័យកីឡាជាកម្លាំងជំរុញមួយដែលធ្វើឱ្យពិភពលោកទាំងមូលបានដឹងអំពីឧត្តមភាពរបស់ជាតិនិងភាពសម្បូរបែបជាលក្ខណៈអំណោយផលនិងជារូបភាពនៃការអភិវឌ្ឍប្រកបដោយសក្តានុពល និងសុខសន្តិភាពពេញ។ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីផ្សារកីឡាអំពីបញ្ហាក្នុងវិស័យកីឡានៅខណ្ឌជ្រោយចង្វារ និងចូលរួមចំណែកផ្តល់នូវដំណោះស្រាយសមស្រប ព្រមទាំងការរំពឹងទុកនៃការអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារផងដែរ។ លទ្ធផលដែលទទួលបានពីការស្រាវជ្រាវនេះគឺមានគោលបំណងផ្តល់នូវសារៈសំខាន់ដូចជា ការផ្តល់ជាទិន្នន័យដែលអាចទុកជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ការជួយជម្រុញការផ្សព្វផ្សាយអំពីភាពចាំបាច់ការចូលរួមចំណែករបស់វិស័យកីឡាលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ និងក្នុងការបញ្ជ្រៀបការយល់ដឹងបន្ថែមពីភាពចាំបាច់នៃវិស័យកីឡា ជាឯកសារជំនួយសម្រាប់ការសិក្សាស្រាវជ្រាវដល់សិស្ស និស្សិតជំនាន់ក្រោយ ជាការពង្រឹងសមត្ថភាពស្រាវជ្រាវនិងទទួលបាននូវការយល់ដឹងបន្ថែម បង្កើនទំនាក់ទំនងល្អ និងស្វែងយល់ពីផ្នែកនៃការអភិវឌ្ឍក្នុងសហគមន៍ ជួយជាទិន្នន័យសម្រាប់ការស្រាវជ្រាវទូទៅ មានមូលដ្ឋានក្នុងការស្វែងរកពីចំណុចខ្លាំង និងចំណុចខ្សោយវិស័យកីឡា បង្កើនការសិក្សាស្វែងយល់បន្ថែមដើម្បីបង្កើនជាទីផ្សារកីឡានិងសកម្មភាពសម្រាប់ជាកំណើនក្នុងការអភិវឌ្ឍជាបន្តបន្ទាប់។

ការសិក្សាការលើកកម្ពស់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីផ្សារកីឡានៅខណ្ឌជ្រោយចង្វារជាការពិចារណាយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសហគមន៍ និងអភិវឌ្ឍវិស័យសេដ្ឋកិច្ច។អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺជាការសាងសង់ ជួសជុល កែលម្អ និងថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំកាយតាមគ្រឹះស្ថានសិក្សា ព្រមទាំងនៅក្នុងសហគមន៍។ ទីផ្សារកីឡាគឺជាសំដៅដល់ការទិញ ឬលក់សម្ភារៈកីឡា ផលិតផលបរិក្ខារកីឡា សំបុត្រ ទស្សនា ចំណីអាហារកីឡា ភេសជ្ជៈកីឡា ទស្សនីយភាពកីឡា ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ការផ្សាយពាណិជ្ជកម្ម ធានារ៉ាប់រង សេវាសុខភាព អ្នកឧបត្ថម្ភគាំទ្រ ការដោះដូរ ការទិញឬលក់កីឡាករពីក្លឹបមួយទៅក្លឹបមួយ។ សរុបមកផលប្រយោជន៍ខាងលើនេះពិតជាបានជួយរំលឹកដល់អ្នកធ្វើផែនការ និងអ្នកសិក្សាស្រាវជ្រាវដែលសិក្សាពាក់ព័ន្ធស្វែងយល់អំពីសារៈសំខាន់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីផ្សារកីឡា រួមទាំងការរួមចំណែកដល់សកម្មភាពសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ។ ដូច្នេះក្នុងបរិបទនេះដោយសារការសិក្សារបស់ប្រជាពលរដ្ឋក្នុងនៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ក៏ដូចជាអ្នករៀបចំផែនការ និងអ្នកសិក្សាស្រាវជ្រាវឱ្យសមស្របមួយសម្រាប់ការអភិវឌ្ឍសហគមន៍ខណ្ឌជ្រោយចង្វារផងដែរ។

## ១.៧. ទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

វិសាលភាពនៃការសិក្សាស្រាវជ្រាវនេះ នឹងអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវដែលផ្តោតលើ

«ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព» ដើម្បីលើកកម្ពស់ដល់ជីវភាពសហគមន៍ ដែលផ្ដោតសំខាន់ទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីផ្សារកីឡា ក្នុងការបំរើសេវាកម្មជូនប្រជាពលរដ្ឋ ព្រមទាំងបង្ហាញឱ្យឃើញអំពីការចូលរួមរបស់ប្រជាពលជាមួយវិស័យកីឡាក្នុងសហគមន៍ផងដែរ។

- ការសិក្សាបច្ចុប្បន្នកំណត់ និងវាយតម្លៃក្នុងការចូលរួមរបស់វិស័យកីឡានៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ។ ក្រៅពីនេះទៅទៀតដើម្បីស្វែងរកការពិតឱ្យកាន់តែស៊ីជម្រៅការសិក្សាបច្ចុប្បគឺដើម្បីស្វែងរកទិន្នន័យ និងវិភាគអំពីការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពក្នុងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយការសិក្សាគឺមិនអាចគ្មានដែនកំណត់នោះទេ ដូច្នេះហើយខាងក្រោមនេះត្រូវបានកំណត់ថាជាដែនកំណត់នៃការសិក្សាស្រាវជ្រាវ។
- វាយតម្លៃនៃការយល់ដឹងអំពីភាសាសកលនៃវិស័យកីឡា និងផ្សព្វផ្សាយអំពីទីផ្សារកីឡាក្នុងការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ ដែលត្រូវបានយកមកវិភាគ។
- សិក្សាលើយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីធ្លាបៃតងសាធារណៈដែលមានស្រាប់ និងថ្មីបន្ថែមទៀតសម្រាប់លើកកម្ពស់វិស័យកីឡាក្នុងពេលបច្ចុប្បន្ន និងអនាគត។
- វិភាគនៃការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពក្នុងការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ។ លើសនេះ ដោយផ្អែកលើទិន្នន័យដែលអាចរកបានសូចនាករដូចជា ការយល់ដឹងរបស់ប្រជាពលរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធកីឡាភាសាសកលនៃវិស័យកីឡា ទីផ្សារកីឡា។

លើសពីនេះទៅទៀតដើម្បីវិភាគទិន្នន័យបឋម ការសិក្សាត្រូវបានកំណត់ចំពោះទំហំសំណាកដែលមានអ្នកឆ្លើយតបចំនួន៣៧៨នាក់។ ដោយផ្អែកលើរូបមន្តគណនាទំហំសំណាកតាមស្ថិតិចំនួនសាកលភាពដោយជ្រើសរើសយកភាពលម្អៀង៥%។ ទោះបីជាការសិក្សាបច្ចុប្បន្នមានកម្រិតក្នុងវិសាលភាព និងគ្របដណ្ដប់របស់វាក៏ដោយប៉ុន្តែការរក្សាការខិតខំប្រឹងប្រែង ពេលវេលា លទ្ធភាពក្នុងការទទួលបានទិន្នន័យ និងឧបសគ្គផ្សេងទៀតក្នុងការសិក្សានេះជាការប៉ុនប៉ងយ៉ាងពេញទំហឹងតាមទិសដៅនៃកម្មវត្ថុដែលបានចែងខាងលើ។

## ១.៨.គម្រោងក្នុងការសិក្សាស្រាវជ្រាវ

**ជំពូកទី១** ៖ គោលបំណងនៃជំពូកនេះបានពណ៌នាផ្នែកមួយចំនួនដូចជា៖ សាវតានៃការសិក្សាស្រាវជ្រាវ ចំណោទនៃបញ្ហា សំណួរស្រាវជ្រាវ គោលបំណងនៃការសិក្សា ការតាងសម្មតិកម្ម សារៈសំខាន់នៃការសិក្សា វិសាលភាព ដែនកំណត់នៃការសិក្សា និងគម្រោងក្នុងកាសិក្សា

ដែលទាក់ទង និងប្រធានបទ ការចូលរួមរបស់កីឡាក្នុងការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព។

**ជំពូកទី២** ៖ គោលបំណងនៃជំពូកនេះ គឺដើម្បីពិនិត្យឡើងវិញនូវទ្រឹស្តីដែលទាក់ទងនឹងបញ្ហានៃការស្រាវជ្រាវ។ ចំពោះគោលបំណងនៃជំពូកនេះត្រូវបានបែងចែកជា៣ផ្នែករួមមាន៖ ការរំលឹកទ្រឹស្តីទាក់ទងនឹងទស្សនាទាន(Conceptual Literature) ទាក់ទងនឹងទស្សនៈវិស័យបេសកម្ម និងគុណតម្លៃនៃវិស័យកីឡា និយមន័យពាក្យគន្លឹះសំខាន់ៗទាក់ទងនឹងគុណតម្លៃនិងសក្តានុពលអភិវឌ្ឍសំដៅ រកភាពពេញចិត្តនិងកត្តានាំឱ្យមានភាពប្រសើរឡើងនៃជីវភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍តាមរយៈវិស័យកីឡា។ នៅក្នុងទ្រឹស្តីដែលមានលក្ខណៈជាក់ស្តែងឬជាបទពិសោធន៍(Empirical Literature)សិក្សាផ្តោតលើសក្តានុពលនៃគុណតម្លៃវិស័យកីឡាដែលបានចូលរួមចំណែកក្នុងដំណើរការយុទ្ធសាស្ត្រនៃការដំណើរការសកម្មភាពលើកកម្ពស់ជីវភាពសហគមន៍។

**ជំពូកទី៣** ៖ គោលបំណងសំខាន់នៃជំពូកនេះគឺដើម្បីបង្ហាញអំពីការអនុវត្តការប្រតិបត្តិដូចជាសកម្មភាពចូលរួមរបស់វិស័យកីឡាដែលបានបង្ហាញថាជាសមិទ្ធផលដើម្បីការអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ដើម្បីបំពេញនូវគោលបំណងជំពូកនេះត្រូវចែកជា៥ផ្នែកសំខាន់ៗ៖ ផ្នែកទី១ ប្រភេទទិន្នន័យ ការកំណត់ទំហំសំណាក និងជ្រើសរើសសំណាក។ ផ្នែកទី២ ប្រភពទិន្នន័យ ផ្នែកទី៣ ឧបករណ៍ស្ថិតិនៃការស្រាវជ្រាវ ផ្នែកទី៤ វិធីសាស្ត្រនៃការវិភាគទិន្នន័យ ផ្នែកទី៥ ភាពជឿជាក់នៃសំណួរស្រាវជ្រាវ។

**ជំពូកទី៤** ៖ គោលបំណងនៃជំពូកនេះគឺដើម្បីបង្ហាញអំពីការវិភាគទិន្នន័យដែលប្រមូលបានពីប្រជាពលរដ្ឋរស់នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ដើម្បីបំពេញនូវគោលបំណងជំពូកនេះត្រូវចែកជា៣ផ្នែកសំខាន់ៗ៖ ផ្នែកទី១ វិភាគពីអត្តសញ្ញាណអ្នកឆ្លើយតប ចំណែកឯផ្នែកទី២ វិភាគពីមធ្យមមេគុណដើម្បីកំណត់រកប្រសិទ្ធភាពនៃភាពលំអៀង និងជាចុងក្រោយ ផ្នែកទី៣ វង្វាស់វិភាគតាម Regression ដើម្បីកំណត់ទំនាក់ទំនងរបស់អថេរឯករាជ្យ និងអថេរពឹងផ្អែក ហើយជាការបកស្រាយលទ្ធផលចុងក្រោយនៃការវិភាគបាន។

**ជំពូកទី៥** ៖ គោលបំណងសំខាន់នៃជំពូកនេះគឺដើម្បីបង្ហាញពីការសិក្សាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីធ្លាបៃតងសាធារណៈដែលមានស្រាប់ និងថ្មីបន្ថែមទៀតសម្រាប់លើកកម្ពស់វិស័យកីឡាក្នុងពេលបច្ចុប្បន្ន និងអនាគត នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ដើម្បីបំពេញនូវគោលបំណងជំពូកនេះត្រូវចែកជា៣ផ្នែកសំខាន់ៗ៖ ផ្នែកទី១ សាវតា ផ្នែកទី២ អត្ថប្រយោជន៍និងការអនុវត្តល្អរបស់វិស័យកីឡា ផ្នែកទី៣ អភិវឌ្ឍទីធ្លាបៃតងសាធារណៈនិងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់លើកកម្ពស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ ផ្នែកទី៤ សេចក្តីសន្និដ្ឋាន។

**ជំពូកទី៦** ៖ គោលបំណងសំខាន់នៃជំពូកនេះគឺសំដៅដល់ការបង្ហាញជាសង្ខេបអំពីការរកឃើញនូវចំណុចសំខាន់ៗនៃការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍។ លើសពីនេះទៅទៀតជំពូកនេះបង្ហាញពីការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព ដែលជាវិសាលភាព សម្រាប់ការសិក្សាស្រាវជ្រាវ និងការសន្និដ្ឋានបន្ថែមទៀត។ដូច្នេះសម្រាប់គោលបំណងនៃជំពូកនេះគឺត្រូវបានបែងចែកជា៣ផ្នែក៖ ផ្នែកទី១ ទាក់ទង និងការរកឃើញលទ្ធផលសំខាន់ៗនៅក្នុងការសិក្សា ផ្នែកទី២ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ផ្នែកទី៣ ការស្រាវជ្រាវនាពេលអនាគត។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## សេចក្តីផ្តើម

តាមការសិក្សានៃជំពូកទី២ ត្រូវបានឧទ្ទិសដល់ការពិនិត្យឡើងវិញនៃទ្រឹស្តី និងបានបង្ហាញអំពីនិយមន័យសេរៀនដែលជាពាក្យគន្លឹះ ហើយជាប្រភពក្នុងការសិក្សាស្រាវជ្រាវលើ ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព ជាការស្វែងយល់ក្នុងការរំលឹកទ្រឹស្តី និងការទាក់ទងទៅនឹងអថេរ និងគោលបំណងនៃខ្លឹមសារមេរៀន។ ជំពូកនេះត្រូវបានបែងចែកជាបីផ្នែកសំខាន់ៗដូចជាផ្នែកទី១ និយាយអំពីគោលគំនិតសំខាន់ៗដែលទាក់ទងនឹងទ្រឹស្តី និយមន័យ ឬពាក្យគន្លឹះសំខាន់ៗ។ ផ្នែកទី២៖ នៅក្នុងទ្រឹស្តីនេះដែលមានលក្ខណៈជាក់ស្តែង ឬបែបពិសោធន៍ ការសិក្សាផ្តោតលើមវិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍របស់ពួកគាត់។ ផ្នែកទី៣៖ ជាចុងក្រោយមានការសន្និដ្ឋានត្រូវបានផ្តល់ឱ្យ។

## ២.១. និយមន័យ ឬពាក្យគន្លឹះ

| ល.រ | វាក្យស័ព្ទ | និយមន័យ | ការរំលឹកស្នាដៃ |
|---|---|---|---|
| ១. | ការយល់ដឹងអំពីការចូលរួមរបស់ប្រជាពលរដ្ឋ | ការយល់ដឹងអំពីការចូលរួមរបស់ប្រជាពលរដ្ឋសំដៅទៅដល់ការយល់ច្បាស់អំពីការសហគមន៍មួយ ដែលបានផ្តល់ផលប្រយោជន៍សហគមន៍ និងប្រជាពលរដ្ឋ។ ហើយការចូលរួមរបស់ប្រជាពលរដ្ឋគឺបានឆ្លុះបញ្ចាំងអំពីវិសាលភាពនៅក្នុងការចូលរួម និងកែលម្អនៅក្នុងសហគមន៍មួយ។ ការចូលរួមរបស់ប្រជាពលរដ្ឋ ដែលជាលទ្ធផលដ៏សំខាន់នៃចំណេះដឹងនិងទំនួលខុសត្រូវរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងការចូលរួមអភិវឌ្ឍការរួមបញ្ចូលគ្នានៃចំណេះដឹងជំនាញ និងគុណតម្លៃ និងការលើកទឹកចិត្ត។ ហើយវាក៏ជាការលើកកម្ពស់គុណភាពនៃការរស់នៅក្នុងសហគមន៍ តាមរយៈការចូលរួមគ្រប់សកម្មភាពទាំងការចូលរួមផ្នែកនយោបាយ និងមិននយោបាយ។ លើសពីនេះទៅទៀតចំណេះដឹង និងទំនួលខុសត្រូវរបស់ពលរដ្ឋរួមបញ្ចូលទាំងសកម្មភាពនៃការខ្វល់ខ្វាយអំពីខ្លួនផ្ទាល់ និង | Alida D( 2021 ) Thomas Ehrlich,( 2000 ) Diana Adela Martin, Eddie Conlon & Brian Bowe( 2021 ) |

| | | | |
|---|---|---|---|
| | | សាធារណៈ ដែលផ្តល់ប្រយោជន៍ដល់ជីវិតផ្ទាល់ខ្លួន និងជាប្រយោជន៍ដល់សង្គមឬសហគមន៍។ រដ្ឋាភិបាលត្រូវបានកំណត់ថាជាស្ថាប័នផ្លូវការនៃសង្គមដែលមានសិទ្ធិអំណាចធ្វើ និងអនុវត្តសេចក្តីសម្រេចដែលចងអំពីបញ្ហាដូចជា ការចែកចាយធនធានការបែងចែកអត្ថប្រយោជន៍ និងបន្ទុក និងការគ្រប់គ្រងជម្លោះ។ | |
| ២. | ហេដ្ឋារចនាសម្ព័ន្ធកីឡា | គឺជាការសាងសង់ ជួសជុល កែលម្អ និងថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំកាយតាមគ្រឹះស្ថានសិក្សា ព្រមទាំងនៅក្នុងសហគមន៍។ | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ |
| ៣. | ភាសាសកលនៃវិស័យ កីឡា | សំដៅដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមកដែលវិស័យកីឡាចាំបាច់ត្រូវតែមានមុនអ្វីៗទាំងអស់ ក្នុងការធ្វើឱ្យប្រជាជនលើសកលលោក ចូលរួមវិភាគទានថែរក្សាសន្តិភាពយូរអង្វែង មិត្តភាពនិងការគោរពគ្នាទៅវិញទៅមកហើយអ្វីៗទាំងនេះនឹងបង្កើតបានបរិយាកាសអំណោយផល ក្នុងការដោះស្រាយបញ្ហាអន្តរជាតិ។ | គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា ឆ្នាំ ២០១៥ |
| ៤. | ទីផ្សារកីឡា | សំដៅដល់ការទិញ ឬលក់សម្ភារៈកីឡា ផលិតផលបរិក្ខារកីឡា សំបុត្រ ទស្សនា ចំណីអាហារកីឡា ភេសជ្ជៈកីឡា ទស្សនីយភាពកីឡា ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយការផ្សាយពាណិជ្ជកម្ម ជានាប៉ាវង សេវាសុខភាព អ្នកឧបត្ថម្ភគាំទ្រ ការដោះដូរ ការទិញឬលក់កីឡាករពីក្លឹបមួយទៅក្លឹបមួយ។ | គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា ឆ្នាំ ២០១៥ |
| ៥. | ទីធ្លាបៃតងសាធារណៈ និង សុខុមាលភាព | ជាកន្លែងថែទាំសុខភាពដែលអាចចូលប្រើបាននិងកម្មវិធីចូលរួមសហគមន៍អាចជួយលើកកម្ពស់អារម្មណ៍នៃភាពជាកម្មសិទ្ធិ និងទំនាក់ទំនងរវាងអ្នករស់នៅ។ នេះអាចនាំឱ្យមានការកើនឡើងនូវអារម្មណ៍នៃគាំទ្រសង្គមនិងសុខុមាលភាពទូទៅ។ | ( De Burca, 2023 ) |

| | | | |
|---|---|---|---|
| | | សុខុមាលភាព គឺជាទិដ្ឋភាពជាមូលដ្ឋាននៃអភិវឌ្ឍន៍ទីក្រុងប្រកបដោយនិរន្តភាព ហើយទីក្រុងនានាជុំវិញពិភពលោកកំពុងប្រកាន់យកគំនិតនេះ ដើម្បីបង្កើតបរិយាកាសទីក្រុងកាន់តែរីករាយ មានសុខភាពល្អ និងអាចរស់នៅបានកាន់តែច្រើន។តាមរយៈការកំណត់កត្តាអាទិភាពដូចជាការចូលរួមសហគមន៍ទីក្រុងនានាអាចបង្កើតគុណភាពជីវិត កាន់តែខ្ពស់សម្រាប់អ្នករស់នៅរបស់ពួកគេ។ | |

## ២.២. ការចូលរួមរបស់វិស័យកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៅក្នុងសហគមន៍

ការចូលរួមត្រូវបានយល់ជាទូទៅថាជាការចូលរួមរបស់ភ្នាក់ងារទាំងពីរគឺខាងក្នុងនិងខាងក្រៅសហគមន៍ដើម្បីធ្វើការរួមគ្នាក្នុងគម្រោងអភិវឌ្ឍន៍ដើម្បីផលប្រយោជន៍រួម( Cornwall ,2006, 2008, Mohan & Stokke,2000 )។ ពាក្យ «ការចូលរួម»ត្រូវបានបកស្រាយតាមវិធីផ្សេងៗគ្នាក្នុងគម្រោងអភិវឌ្ឍដើម្បីផលប្រយោជន៍រួម( Cornwal,2006,2008 Mohan and stockke,2000 )។ ពាក្យ «ការចូលរួម» អាចត្រូវបានបកស្រាយតាមវិធីផ្សេងៗគ្នាអាស្រ័យលើបរិបទ បានបញ្ជាក់ពីកម្រិត ឬកម្រិតនៃការចូលរួមផ្សេងៗគ្នាចំនួនប្រាំពីររួមមាន៖

- ការចូលរួមតាមរយៈការប្រើប្រាស់សេវាមួយប៉ុណ្ណោះ(ដូចជាកាប្រកបមុខរបរផ្សេងៗ)
- ការចូលរួមតាមរយៈការចូលរួមចំណែក(ឬការទាញយក)នៃថវិកា សម្ភារៈ និងកម្លាំងពលកម្ម។
- ការចូលរួមផ្តល់ការពិគ្រោះ
- ការចូលរួមទទួលយកការសម្រេចចិត្តរបស់អ្នកដទៃ
- ការចូលរួមក្នុងការផ្តល់សេវាជាមួយភាគីដទៃ
- ការចូលរួមអនុវត្តនូវអ្វីដែលទទួលបានសិទ្ធ
- ការចូលរួមក្នុងការសម្រេចចិត្តនៅពិតប្រាកដនៅគ្រប់ដំណាក់កាលរួមទាំងការកំណត់អត្តសញ្ញាណលើបញ្ហាផ្សេងៗ ការធ្វើផែនការ ការអនុវត្តន៍ និងការវាយតម្លៃ។ ( Shaeffer1994)

កីឡាជាផ្នែកមួយដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងសាមគ្គី និងមិត្តភាពដែលជាចូលរួមចំណែកក្នុងការបង្កើនមូលធនសង្គម និងសម្រេចបាននូវសុខដុមនីយកម្មក្នុងសង្គមជាតិ។ គន្លឹះសំខាន់ក្នុងការចូលរួមធ្វើឱ្យវិស័យកីឡាមានការអភិវឌ្ឍរួមមាន ការផ្តល់ឱកាសល្អលើការផ្លាស់ប្តូរលើវិស័យជាច្រើនទាំងបច្ចេកទេសនៃការរៀបចំ និងបទពិសោធន៍នៅក្នុងការប្រកួតដែលជាម៌តកវប្បធម៌ ទំនៀមទម្លាប់ និងជាសិល្បៈការពារខ្លួនបែបប្រពៃណីរបស់ប្រជាជាតិនីមួយៗ បន្តលើក

កម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឲ្យមានសុខភាព និងសុខុមាលភាពល្អ កាយសម្បទាមាំមួន ឆន្ទៈមោះមុត អំណត់ព្យាយាម មានវិន័យ មានស្មារតីក្រុមគំនិតច្នៃប្រឌិត និងមានការតស៊ូស្វិតស្វាញ សំដៅដណ្ដើមបានលទ្ធផលល្អប្រសើរ ក្នុងការប្រកួតកីឡាលើឆាកអន្តរជាតិ» ការកសាងមនុស្សគ្រប់រូប ឱ្យមានសុខភាព និងមានជីវភាពស្របតាមពាក្យស្លោក «កីឡារស់ប្រកបដោយសុខដុមរមនា ក្នុងសង្គមក្រោមម្លប់សន្តិភាព» ព្រមទាំងបន្តជំរុញចលនា «យុវជនម្នាក់ ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត» (Moey Cambodia)។ ការលើកកម្ពស់សុខុមាលភាពសង្គមដោយយោងតាមអ្នកវិទ្យាសាស្ត្រជាច្រើនរូបបានបង្ហាញថា ការហាត់កីឡាផ្តល់នូវអត្ថប្រយោជន៍ជាច្រើនចំពោះរាងកាយ និងសរីរាង្គរបស់មនុស្ស។ វាជំរុញឱ្យរាងកាយបញ្ចេញនូវសារជាតុគីមីម្យ៉ាងដែលមានឈ្មោះថា អង់ដូហ្វីន ដែលជួយបំបាត់ភាពតានតឹង ការឈឺចាប់ និងលើកកម្ពស់អារម្មណ៍វិជ្ជមាន។ លើសពីនេះ ការហាត់ប្រាណជួយពង្រឹងទំហំសាច់ដុំ ភាពធន់ និងធ្វើឱ្យសាច់ដុំកាន់តែរឹងមាំ។ ជាពិសេស ជួយកាត់បន្ថយបញ្ហាស្រេក និងលើសទម្ងន់ ការឡើងឈាម ជំងឺគាំងបេះដូង ជំងឺដាច់សរសៃឈាមខួរក្បាល និងបញ្ហាស្ត្រេស។ ការអភិវឌ្ឍក្នុងសហគមន៍ តាមរយៈសកម្មភាពកីឡានាំឱ្យកីឡាករយល់អំពីអត្ថប្រយោជន៍នៃការធ្វើការងារជាក្រុម។ ពិសេស នៅជីវិតជាក់ស្តែង កីឡាករអាចយកស្មារតីបំពេញការងារជាក្រុមរបស់ខ្លួន ដើម្បីចូលរួមអភិវឌ្ឍសហគមន៍ និងស្ថាប័ន ដែលគាត់បំពេញការងារ។ តាមរយៈសកម្មភាពនេះ ពួកគេអាចក្លាយជាចំណែកមួយនៃការអភិវឌ្ឍសង្គមមួយឱ្យមានអរិយធម៌កាន់តែខ្ពង់ខ្ពស់ ដែលជំរុញឱ្យសង្គមមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ នៅពេលដែលយុវជនងាកមកចាប់អារម្មណ៍នឹងការលេងកីឡាក្នុងពេលទំនេរ នេះគឺជាជោគជ័យដ៏ធំមួយក្នុងការកាត់បន្ថយវិបត្តិសង្គម ព្រោះយុវជននឹងមិនចាប់អារម្មណ៍ការសេពគ្រឿងញៀន និងអំពើអបាយមុខផ្សេងៗ។ ចំណុចនេះ ជះឥទ្ធិពលវិជ្ជមានយ៉ាងធំសម្រាប់សង្គមជាតិ ព្រមទាំងអាចកាត់បន្ថយបញ្ហាអន្តិសុខផ្សេងៗផងដែរ។

ការចូលរួមរបស់សហគមន៍ជាវិស័យកីឡា ក្នុងការអភិវឌ្ឍសហគមន៍ គឺជាដំណើរការរួមនៃមូលដ្ឋានមនុស្សដែលចូលរួមក្នុងការសម្រេចចិត្តដោយចាប់ផ្តើមពីការកំណត់ក្នុងការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ។ យោងតាមការរំលឹកលើទ្រឹស្តីខាងលើ បានបញ្ជាក់ឱ្យឃើញថាវិស័យកីឡាពិតជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍជីវភាពសហគមន៍ដែលមានភាពទាក់ទងជាមួយគោលបំណងនៃខ្លឹមសារមេរៀនរួមជាមួយនឹងការយល់ដឹងរបស់ ប្រជា-ពលរដ្ឋ ការផ្តល់ការសហការ ការបង្កើនប្រសិទ្ធភាព ការប្តេជ្ញាចិត្ត និងការចូលរួមចំណែករបស់ប្រជាពលរដ្ឋ។

### ២.២.១. ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព

ការដែលត្រូវបានប្រើប្រាស់ជាទូទៅ បានកំណត់និមយន័យនៃ "ការចូលរួមរបស់ប្រជាពលរដ្ឋ" គឺជាសកម្មភាពជាបុគ្គល ឬជាក្រុម ដែលកើតឡើងក្នុងដំណើរការនានាដែលបុគ្គល ឬក្រុមអ្នកពាក់ព័ន្ធទាំងនោះ បានរួមចំណែក ឬមានឥទ្ធិពលក្នុងដំណើរការកំណត់អាទិភាពលើបញ្ហាអ្វីមួយ ដូចជាការរៀបចំគោលនយោបាយ ការវិភាជន៍ និងប្រើប្រាស់

ធនធាន ក្នុងការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសាធារណៈ។ ការចូលរួមប្រជាពលរដ្ឋមិនត្រឹមតែជាការស្តាប់នូវយោបល់របស់ប្រជាពលរដ្ឋ នៅក្នុងសហគមន៍ និងអ្នកពាក់ព័ន្ធប៉ុណ្ណោះទេ តែជាការទទួលខុសត្រូវទៅវិញទៅមក (ធនាគារពិភពលោកៈគណនេយ្យភាពសង្គមក្នុងការផ្តល់សេវាសាធារណៈ ឆ្នាំ២០០៤)។

នៅចំកណ្តាលនៃនគរូបនីយកម្មយ៉ាងឆាប់រហ័ស ការដាក់បញ្ចូលទីធ្លាសាធារណៈពណ៌បៃតងបានលេចចេញជាទិដ្ឋភាពសំខាន់នៃការអភិវឌ្ឍន៍ទីក្រុងប្រកបដោយនិរន្តរភាព។ ទីធ្លាសាធារណៈពណ៌បៃតង រួមទាំងសួនច្បារ សួនច្បារ ផ្លូវបៃតង និងតំបន់អភិរក្សធម្មជាតិ ផ្តល់នូវតុល្យភាពដ៏ស្រស់ស្រាយចំពោះផ្ទាំងគំនូរជាក់ស្តែងនៃជីវិតទីក្រុង។ ពួកវាបម្រើមិនត្រឹមតែជាការកែលម្អសោភ័ណភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសមាសធាតុសំខាន់សម្រាប់និរន្តរភាពបរិស្ថាន និងសុខុមាលភាពរបស់ប្រជាជនទីក្រុងផងដែរ។ សារៈសំខាន់នៃភាពបៃតងក្នុងទីក្រុងគឺមានលក្ខណៈចម្រុះ ដែលគ្របដណ្តប់លើអត្ថប្រយោជន៍ផ្នែកបរិស្ថាន ផ្លូវចិត្ត និងរាងកាយ។ នៅលើកម្រិតអេកូឡូស៊ី បន្លែអាចកាត់បន្ថយឥទ្ធិពលកោះកំដៅក្នុងទីក្រុងដោយផ្តល់ម្លប់ និងកាត់បន្ថយសីតុណ្ហភាពព័ទ្ធជុំវិញ។ ពួកវាក៏ដើរតួជាកាបូនលិច ស្រូបយកកាបូនឌីអុកស៊ីត និងបញ្ចេញអុកស៊ីហ្សែន ដោយហេតុនេះ ប្រយុទ្ធប្រឆាំងនឹងការបំពុល និងរួមចំណែកធ្វើឱ្យខ្យល់ស្អាត។ ជីវចម្រុះរីកដុះដាលនៅក្នុងទីធ្លាបៃតងទាំងនេះដែលផ្តល់នូវជម្រកសម្រាប់ប្រភេទសត្វផ្សេងៗចំពេលមានការអភិវឌ្ឍន៍ទីក្រុង (Certification, n.d.)។

តាមផ្លូវចិត្ត លំហបៃតងត្រូវបានទទួលស្គាល់សម្រាប់លក្ខណៈសម្បត្តិជួសជុលរបស់វា ដែលផ្តល់ឱ្យអ្នករស់នៅក្នុងទីក្រុងនូវការរត់គេចពីភាពអ៊ូអរនៃជីវិតនៅទីក្រុង។ វត្តមាននៃរុក្ខជាតិបៃតងដែលរីករាលដាល និងឱកាសសម្រាប់សកម្មភាពកម្សាន្តជំរុញអារម្មណ៍សហគមន៍ និងកែលម្អសុខភាពផ្លូវចិត្ត។ ជាងនេះទៅទៀត តំបន់ទាំងនេះលើកទឹកចិត្តឱ្យមានសកម្មភាពរាងកាយ ដែលជាកត្តាសំខាន់ក្នុងការកំណត់ទីក្រុង ដែលរបៀបរស់នៅបែបស្ងប់ស្ងាត់មានជាទូទៅ (Certification, n.d.)។ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងបៃតងនេះ នឹងបញ្ចូលការពិនិត្យឡើងវិញលើវិស័យគន្លឹះដែលមានសារៈសំខាន់ដល់សុខុមាលភាព និងមុខងារនៃតំបន់ក្រុង និងជាវិស័យដែលផ្តល់ឱកាសក្នុងការកាត់បន្ថយការបំពុលបរិស្ថាន និងបំភាយឧស្ម័នកាបូនិចនៅក្នុងបរិកាសសម្រាប់បរិយាប័ន្នសង្គម (ឯកសារណែនាំពីដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ឆ្នាំ២០១៦)។

### ២.២.២. ហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព

ហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីធ្លីបៃតងសាធារណៈមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាជន។ ការរចនាទីក្រុងដែលផ្តោតលើមនុស្ស និងបរិស្ថានបៃតងអាចជួយបង្កើនសុខភាពសាធារណៈ និងបន្ថយផលប៉ះពាល់បរិស្ថាន។ ទីក្រុង Vancouver គឺជាគំរូមួយក្នុងការរចនាទីក្រុងដែលផ្តោតលើមនុស្ស

និងបរិស្ថានបៃតង។ ការរចនានេះផ្តោតលើការបង្កើតបរិយាកាសដែលអាចចូលដំណើរការបាន រីករាយ និងអំណោយផលដល់សុខុមាលភាពសហគមន៍(De Burca, 2024)។

នៅកម្ពុជា ការអភិវឌ្ឍន៍ទីក្រុងបានបង្កើតបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះហេដ្ឋារចនាសម្ព័ន្ធ និងសេវានៅទីប្រជុំជន ការកកស្ទះចរាចរណ៍ និងកង្វះកន្លែងចតយានយន្ត កំណើនទឹកលិចនៅទីប្រជុំជន ការថយចុះកន្លែងសាធារណៈ និងផលប៉ះពាល់បរិស្ថានអវិជ្ជមាន(Pinkie, 2020)។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ទីក្រុងបៃតងគឺជាកត្តាសំខាន់សម្រាប់ការរស់នៅក្នុងតំបន់ទីក្រុងប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព(ឯកសារណែនាំពីដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ឆ្នាំ២០១៦)។

ការរួមបញ្ចូលហេដ្ឋារចនាសម្ព័ន្ធកីឡា និងទីធ្លីបៃតងសាធារណៈក្នុងការរៀបចំផែនការទីក្រុងអាចជួយបង្កើនសុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាជន។ ការរចនាទីក្រុងដែលផ្តោតលើមនុស្ស និងបរិស្ថានបៃតងអាចជួយបង្កើនសុខភាពសាធារណៈ និងបន្ថយផលប៉ះពាល់បរិស្ថាន។

## ២.២.៣. ភាសាសកលនៃវិស័យកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព

ភាសាសកលនៃវិស័យកីឡា សំដៅដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក ដែលវិស័យកីឡាចាំបាច់ត្រូវតែមានមុនអ្វីៗទាំងអស់ក្នុងការធ្វើឱ្យប្រជាជនលើសកលលោក ចូលរួមវិភាគទាន់ថែរក្សាសន្តិភាពយូរអង្វែង មិត្តភាព និងការគោរពគ្នាទៅវិញទៅមក ហើយអ្វីៗទាំងនេះនឹងបង្កើតបានបរិយាកាសអំណោយផលក្នុងការដោះស្រាយបញ្ហាអន្តរជាតិ(គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡាឆ្នាំ២០១៥)។ កីឡាត្រូវបសនកំណត់ចរិតលក្ខណៈរបស់តាមរយៈការលេងព្រមទាំងជាតុផ្សំចុងក្រោយគឺរួមបញ្ចូលនូវសញ្ញាណនៃលទ្ធផល និងការវិនិច្ឆ័យចំពោះការសម្តែងកីឡា(ទេសចរណ៍កីឡា ២០១២)។ ទីធ្លាបៃតងសាធារណៈ មានសារៈសំខាន់ក្នុងការលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាជន យោងតាមអង្គការសុខភាពពិភពលោក (WHO) ទីក្រុងនីមួយៗគួរតែមានផ្ទៃដីបៃតងយ៉ាងតិច ៩ ម៉ែត្រការ៉េសម្រាប់មនុស្សម្នាក់។ ប៉ុន្តែសម្រាប់រាជធានីភ្នំពេញ ទីធ្លាសាធារណៈមានតិចជាង ១ ម៉ែត្រការ៉េសម្រាប់មនុស្សម្នាក់។ ការមានទីធ្លាបៃតងសាធារណៈច្រើនកន្លែងគឺជា ជាតុសំខាន់ក្នុងការលើកកម្ពស់ការធ្វើចល័តភាពយ៉ាងសកម្មក្នុងទីក្រុង។

ការបង្កើតនូវការប្រមូលផ្តុំកីឡាសំខាន់ៗ ដែលជាលកត្តាទាក់ទាញទេសចរ និងសម្បទាទេសចរណ៍ ត្រូវបានគេអះអាងថាជាយុទ្ធសាស្ត្រមួយដែលពេញនិយមបំផុតសម្រាប់ការរៀបចំទិដ្ឋភាពទីក្រុងឡើងវិញ។ អត្ថប្រយោជន៍ជាក់ស្តែងនៃនិន្នាការនេះបានធ្វើឱ្យវិស័យអចលនវត្ថុមានការកើនឡើងនៅក្នុងទីក្រុង ប៉ុន្តែវិស័យទេសចរណ៍ និងកីឡា ក៏បាន

ដើរតួយ៉ាងសកម្មជាកត្តាលើកកម្ពស់ដល់យុទ្ធសាស្ត្រនេះផងដែរ។ ការរៀបចំទេសភាពទីកន្លែងឡើងវិញ គឺការធ្វើជាម្ចាស់ផ្ទះនៃព្រឹត្តិការណ៍សំខាន់ៗ។ ព្រឹត្តិការណ៍កីឡាជាទូទៅមានភាពទាក់ទាញ និងការយកចិត្តទុកដាក់លើប្រព័ន្ធផ្សព្វផ្សាយបន្តផ្ទាល់ពីសកម្មភាពនៃព្រឹត្តិការណ៍ទាំងនោះ ក៏មានទំនោរទាក់ទាញទេសចរផងដែរ។ កិច្ចសហការផ្សព្វផ្សាយពាណិជ្ជកម្មជាមួយ និងអ្នកឧបត្ថម្ភកីឡាអូឡាំពិច ការផ្សាយបន្តផ្ទាល់ ការទស្សនាកម្មវិធីព័ត៌មានកីឡាមុនគេបង្អស់ក្នុងអំឡុងពេលព្រឹត្តិការណ៍ និងក្រោយពីការប្រកួត ការផ្តល់ការផ្សាយបន្តផ្ទាល់តាមទូរទស្សន៍ ការផ្តល់បរិក្ខារសំខាន់ៗ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយប្រឌិតក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយពិត ការគាំទ្រចំពោះការអភិវឌ្ឍពាណិជ្ជកម្ម។ (ទេសចរណ៍កីឡា ឆ្នាំ២០១២)

បង្កើនភាពរឹងមាំ និងលើកកម្ពស់សុខភាពល្អដែលជាទ្រព្យសម្បត្តិដ៏ប្រពៃ និងជាកត្តាកំណត់ដ៏សំខាន់នៃផលិតភាព ពលកម្ម និងការកសាងមូលធនមនុស្សសម្រាប់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ប្រកបដោយភាពធន់ និងចីរភាព។ ប្រជាពលរដ្ឋដែលមានសុខភាពល្អរស់នៅដោយ សេចក្តីរីករាយ ងាយចាប់យកចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ ព្រមទាំងមានការតាំងចិត្ត និងក្តីសង្ឃឹមខ្ពស់ក្នុងការបង្កើនជំនាញ និងមូលធនមនុស្សតាមរយៈការសិក្សាបន្ថែមពេញមួយជីវិត ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះដឹង និងបច្ចេកវិទ្យាជាប្រចាំសម្រាប់រួមចំណែកដល់ការផ្គត់ផ្គង់កម្លាំងពលកម្ម ដែលមានគុណភាព និងផលិតភាពខ្ពស់។

## ២.២.៤. ទីផ្សារកីឡា និងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព

កីឡា គឺជាវិធីសាស្ត្រដែលមានអានុភាពបំផុត ក្នុងការបង្កើតអត្តសញ្ញាណទីកន្លែង ប្រៀបដូចជាវប្បធម៌ដែលជាកត្តាគន្លឹះក្នុងការសំគាល់ពីទីកន្លែង។ តាមរយៈការបំលែងស្តង់ដារវប្បធម៌នៃកីឡា អ្នកស្វែងរកទីផ្សារទីកន្លែងអាចពង្រីកបែបផែននៃការរស់នៅក្នុងទីកន្លែងនោះ។ នៅក្នុងបរិបទកីឡា គម្រោងនេះអាចត្រូវបានធ្វើរួចរាល់ដោយការអភិវឌ្ឍ(១)សម្បទាសំខាន់ៗ(២)ព្រឹត្តិការណ៍សំគាល់(៣)ការផ្តោតលើយុទ្ធសាស្ត្រ និងគោនយោបាយទេសចរណ៍ និង(៤)ការពង្រីកឱកាសវប្បធម៌ និងការកំសាន្តជាមួយនិងគោលដៅមួយច្បាស់លាស់។ (ទេសចរណ៍កីឡា ឆ្នាំ២០១២)

កីឡាជាវិស័យមួយដែលចូលរួមយ៉ាងសកម្ម ក្នុងការលើកមុខមាត់ប្រទេសក្នុងទីផ្សារសាកលលោក (តាមរយៈការចូលរួមធ្វើជាម្ចាស់ផ្ទះព្រឹត្តិការណ៍ធំៗ ការបង្ហាញខ្លួនលើឆាកអន្តរជាតិ ដែលអាចទាក់ទាញវិនិយោគដល់ប្រទេសដូចជាការបង្កើនទំហំជំនួញនិងពាណិជ្ជកម្មដើម្បីជំរុញក្បាលម៉ាស៊ីនសេដ្ឋកិច្ច)។ បង្កើនការទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកទស្សនា(អាចដាក់បញ្ចូលគោលដៅទេសចរណ៍ដែលមិនមានគេស្គាល់ទៅក្នុងផែនទី អាចជួយពង្រឹងឬកែលម្អមុខមាត់ថ្មីរបស់ប្រទេសដើម្បីទាក់ទាញទេសចរ។ ព្រឹត្តិការណ៍កីឡាក៏បាននាំមកនូវ

ភាពសប្បាយរីករាយ រំភើបអស្ចារ្យនិងទទួលបាននូវអារម្មណ៍ប្លែកជាមួយវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី)។ កែលម្អហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច(ព្រឹត្តការណ៍ធំៗតម្រូវឱ្យមានការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ហើយប្រសិនបើមានការគ្រប់គ្រងត្រឹមត្រូវវាអាចនឹងមានលទ្ធផលវិជ្ជមាននិងយូរអង្វែងដល់សហគមន៍និងប្រទេសជាតិ។ លើកកម្ពស់សេដ្ឋកិច្ចរយៈពេលវែង (ព្រឹត្តិការណ៍កីឡាធំៗអាចជះឥទ្ធិពលយ៉ាងឆាប់រហ័សនិងមានរយៈពេលវែងដល់សេដ្ឋកិច្ច។សកម្មភាពនិងការវិនិយោគតម្រូវឱ្យមានទាំងមុនពេល ក្នុងកំលុងពេល និងពេលបន្ទាប់ពីព្រឹត្តិការណ៍ដែលផ្តល់ឱកាសការងារបានយ៉ាងច្រើនពិសេសបង្កើនឱកាសជំនួញថ្មីៗដល់ក្រុមហ៊ុនឯកជន។ ហេដ្ឋារចនាសម្ព័ន្ធដែលបានកែលម្អរួចក៏អាចទាក់ទាញក្រុមហ៊ុនថ្មីៗនិងអាចឱ្យប្រជាជននិងពាណីជ្ជកម្មធ្វើអាជីវកម្មកាន់តែមានប្រសិទ្ធភាពផងដែរ។(Olympic Cambodia)វិស័យកីឡាដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ វប្បធម៌ទេសចរណ៍នយោបាយការទូត និងសេដ្ឋកិច្ចសង្គម។ ដើម្បីពង្រឹងយុទ្ធសាស្ត្រនៃដំណើរការសកម្មភាពអភិវឌ្ឍន៍ឱ្យទទួលបានជោគជ័យៈ

- ស្ថាប័នជាតិកំពូលៗ និងក្រសួង មន្ទីរ អង្គភាពរដ្ឋត្រូវយកចិត្តទុកដាក់រួមចំណែកធ្វើលំហាត់អប់រំកាយ និងកីឡា និងបង្កើតក្លឹបកីឡាជំនាញ ដើម្បីសុខភាព និងសមត្ថភាពការងារជាមួយនឹងការបង្កើតក្លឹបមិត្តភាព សាមគ្គីផ្ទៃក្នុងបង្កើនបរិយាកាសសុខដុមរមនាការងារ។

- កសាងផែនការរៀបចំគោលនយោបាយថវិកាដើម្បីត្រៀមរៀបចំសកម្មភាពព្រឹត្តិការណ៍កីឡាផ្សេងៗដើម្បីបង្ហាញមុខមាត់ប្រទេសជាតិនឹងទាក់ទាញទេសចរណ៍ជាតិ-អន្តរជាតិឱ្យស្គាល់ពីសក្កានុពល និងចង់មកទស្សនាដែលជាឱកាសដល់ប្រជាពលរដ្ឋអាចបង្កើនចំណូល

- ពង្រឹងយន្តការបណ្តុះបណ្តាលសមត្ថភាពរបស់អត្តពលិកដើម្បីបង្កើនសន្ទុះនៃភាពល្បីល្បាញរបស់កីឡាកម្ពុជាឱ្យឆ្ពោះទៅកាន់កម្រិតស្តង់ដារអន្តរជាតិ

- បង្កើនការរៀបចំ និងទទួលធ្វើជាម្ចាស់លើព្រឹត្តិការណ៍ធំៗដែលជាឱកាសសម្រាប់ការទាក់ទាញទេសចរណ៍ចូលមកទស្សនា

- បន្តផ្សព្វផ្សាយពីភាពរីកចម្រើននៃវិស័យកីឡាដោយរួមបញ្ចូលទាំងវប្បធម៌របស់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ (https://pressocm.gov.kh/wp-24-Aug-2023.pdf )។

ចុងក្រោយនេះ ការអភិវឌ្ឍយ៉ាងទូលំទូលាយនៃទំនាក់ទំនងកីឡាជាមួយ និងការកំសាន្ត និងសេវាកម្ម វប្បធម៌គឺការប្រើប្រាស់ដើម្បីធ្វើការផ្សព្វផ្សាយទីកន្លែងដែលផ្តោតទៅលើកីឡា។ ដោយមានការគាំទ្រពីកីឡាជំនាញកម្រិតខ្ពស់ ដើម្បីអភិវឌ្ឍសីលធម៌កីឡា

ជាមួយនិង ទីកន្លែងមួយចំនួនដូចជា ចំណត និងការអភិវឌ្ឍន៍មាត់ច្រាំងសមុទ្រ ដែលលើស្ទួយសកម្មភាពកីឡាមួយចំនួនដូចជា ការរត់ត្រឹកៗ ការជិះកង់ និងការជិះទូកក្តោង។ គេបានប្រើប្រាស់យុទ្ធសាស្រ្តនេះ ដើម្បីលើកស្ទួយសហគមន៍របស់ខ្លួនថាជាសហគមន៍សុខភាពសកម្ម ទាំងផ្នែកអត្តសញ្ញាណផ្ទាល់ខ្លួន។(ទេសចរណ៍កីឡា ឆ្នាំ២០១២)

## ២.៣. ការរំលឹកឡើងវិញនៃវិធីសាស្រ្តស្រាវជ្រាវ

ក្នុងចំនុចនេះគឺជាចំនុចដែលបង្ហាញអំពីវិធីសាស្រ្តកន្លងមករបស់អ្នកស្រាវជ្រាវមុនៗ ដែលនឹងពន្យល់ពីវិធីសាស្រ្តនៃការប្រមូលទិន្នន័យ និងការវិភាគរបស់អ្នកស្រាវជ្រាវកន្លងមក។ ផ្នែកសំខាន់ នៃនិក្ខេបបទ ឬឯកសារស្រាវជ្រាវរបស់អ្នកស្រាវជ្រាវនឹងធ្វើឱ្យអ្នកស្រាវជ្រាវនាពេលអនាគតមានងាយស្រួល និងយល់ពីអ្វីដែលអ្នកសរសេរបានរៀបចំ និងអនុញ្ញាតឱ្យអ្នកអានវាយតម្លៃ និងមានភាពជឿជាក់លើប្រធានបទនិក្ខេបបទរបស់អ្នក។

តាមរយៈការសិក្សាកន្លងមកបានបង្ហាញឱ្យឃើញថា អ្នកសិក្សាស្រាវជ្រាវនិយមប្រើប្រាស់វិធីសាស្រ្តស្រាវជ្រាវតាមបែបបរិមាណវិស័យ ហើយប្រើប្រាស់ការប្រមូលទិន្នន័យតាមបែប២ប្រភេទ គឺប្រើប្រាស់ទិន្នន័យទី១ ដែលប្រមូលដោយផ្ទាល់តាមរយៈការសំណួរ និងសម្ភាសន៍ប្រជាពលរដ្ឋ។ ចំណែកឯទិន្នន័យទី២ ត្រូវបានប្រមូលមកពីការសិក្សាស្រាវជ្រាវមុនៗ មិនចំពោះតែទិន្នន័យដែលទទួលពាក់ព័ន្ធនឹងការសិក្សានៅទីតាំងដូចគ្នានោះទេ ក៏ប៉ុន្តែវាអាស្រ័យការសិក្សាផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងប្រធានបទរបស់យើង ដើម្បីការប្រៀបធៀបអំពីភាពត្រឹមត្រូវនៃសិក្សាស្រាវជ្រាវក៏ដូចជាពិនិត្យលើភាពប្រែប្រួលនៃសេវាកម្ម។

(រឿន ចន្ទារ៉ូ,ឆ្នាំ២០២១)បានស្រាវជ្រាវនិងវិភាគលើភាពពេញចិត្តរបស់របស់ប្រជាពលរដ្ឋនៅក្នុងភូមិបន្ទិចប្រាសាទ តាមរយៈការសិក្សារបស់គេបានបង្ហាញថាគេបានជ្រើសរើសវិធីសាស្រ្តស្រាវជ្រាវតាមបែបបរិមាណវិស័យដើម្បីវាយតម្លៃលើភាពមានទំនាក់ទំនងគ្នារវាងអថេរឯករាជ្យនិងអថេរពឹងផ្អែក។ ដោយក្នុងប្រធានបទនេះគេបានបែងចែកអថេរជា២ផ្នែក ដែលផ្នែកទី១ គឺអថេរឯករាជ្យ(DV)ភាពពេញចិត្ត ផ្នែកទី២ជាអថេរពឹងផ្អែក ដែលអថេរពឹងផ្អែកបានបែងចែកជា៥ទៀតយកមកវិភាគរួមមានៈភាពជឿជាក់ មន្ត្រីរាជការ ការចំណាយថ្លៃសេវានិងពេល គ្រឿងបរិក្ខា ភាពទទួលខុសត្រូវ។ តាមរយៈលទ្ធផលចុងក្រោយនៃការស្រាវជ្រាវនេះបានបង្ហាញថាអថេរឯករាជ្យនិងអថេរពឹងផ្អែកមានភាពទាក់ទងគ្នា តាមរយៈការទទួលបានការវិភាគពីព្រជាពលរដ្ឋចំនួន៣១៨នាក់ ដោយវិភាគតាមបែបMultiple Regression(Tri,2021)។បានធ្វើការស្រាវជ្រាវលើ ការចូលរួមរបស់ប្រជាពលរដ្ឋនៅជនបទថ្មី ការអភិវឌ្ឍស្រុក Nha Be នៅចន្លោះឆ្នាំ២០១៦-២០២០ នឹងបានបង្ហាញថាតាមរយៈការស្រាវជ្រាវរបស់គេបានជ្រើសរើសវិធីសាស្រ្តតាមបែបបរិមាណវិស័យដើម្បីវាយតម្លៃលើភាពមានទំនាក់ទំនងគ្នារវាងអថេរឯករាជ្យនិងអថេរពឹងផ្អែក។ ដោយក្នុងប្រធានបទរបស់គេបានបែងចែកអថេរជា២ផ្នែក ដែលផ្នែកទី១គឺអថេរឯករាជ្យ(DV)ការពេញចិត្តរបស់ប្រជាពលរដ្ឋ និងផ្នែកទី២ជាអថេរពឹងផ្អែក ឌែលអថេរពឹងផ្អែកបានបែងចែកជា៦ទៀតដើម្បីយកមកវិភាគរួមមានៈគោលបំណងនៃការចូលរួម សកម្មភាពនៃការចូលរួម ប្រធានបទនៃការចូលរួម ភាពវិជ្ជមាន ប្រសិទ្ធភាព

ការចូលរួមរបស់ប្រជាពលរដ្ឋ។ តាមរយៈលទ្ធផលចុងក្រោយនៃការស្រាវជ្រាវនេះបានបង្ហាញថា អថេរឯករាជ្យនិងអថេរពឹងផ្អែកមានភាពពាក់ព័ន្ធគ្នាតាមរយៈការទទួលបានការវិភាគពីប្រជាពលរដ្ឋចំនួន៩០០នាក់ដោយវិភាគតាមបែបMultiple Regression (Efron et al,2004)។ លើសពីនេះបានធ្វើការស្រាវជ្រាវលើ សព្វវចនាអធិប្បាយអន្តរជាតិនៃសង្គមនិងវិទ្យាសាស្ត្រខាងឥរិយាបទឆ្នាំ ២០១៥ នឹងបង្ហាញថាតាមរយៈការសិក្សាស្រាវជ្រាវរបស់គាត់បានជ្រើសរើសវិធីសាស្ត្រតាមបែបបរិមាណវិស័យដើម្បីវាយតម្លៃលើភាពមានទំនក់ទំនងគ្នារវាអថេរឯករាជ្យនិងអថេរពឹងផ្អែក។ ដោយធ្វើការវិភាគពីអ្នកឆ្លើយតបចំនួន១០០នាក់។ ហើយ(Ha Minh Tri) លើកមកសរសេរនិងវិភាគឡើងវិញនៅឆ្នាំ២០១២ ពីការពេញចិត្តរបស់ប្រជាពលរដ្ឋជាមួយរាជរដ្ឋាភិបាលក្នុងប្រទេសអាហ្សង់ទីន នឹងបង្ហាញថាតាមរយៈការស្រាវជ្រាវគេបានជ្រើសរើសវិធីសាស្ត្រតាមបែបបរិមាណវិស័យ ដើម្បីវាយតម្លៃលើភាពមានទំនាក់ទំនងគ្នារវាងអថេរឯករាជ្យនិងអថេរពឹងផ្អែក។ ដោយក្នុងប្រធានបទរបស់គេបានបែងចែកអថេរជា២ផ្នែក ដោយអថេរទី១គឺអថេរឯករាជ្យ(DV)ភាពស្មោះត្រង់របស់ថ្នាក់ដឹកនាំមូលដ្ឋាននិងផ្នែកទី២ជាអថេរពឹងផ្អែក ដែលអថេរពឹងផ្អែកបែងចែកជា៥ដើម្បីយកមកវិភាគរួមមាន៖ ការរំពឹងទុករបស់ប្រជាពលរដ្ឋ ការយល់ឃើញនៃសេវាកម្មគ្រប់គ្រងមូលដ្ឋានប្រកបដោយគុណភាព។ តាមរយៈលទ្ធផលចុងក្រោយនៃការការស្រាវជ្រាវនេះបានបង្ហាញថា អថេរឯករាជ្យនងអថេរពឹងផ្អែកមានភាពពាក់ព័ន្ធគ្នា តាមរយៈការទទួលបានការវិភាគពីប្រជាពលរដ្ឋចំនួន១០០នាក់ ដោយវិភាគតាមបែបMultiple Regression។

## ២.៤. គោលគំណិតនៃការស្រាវជ្រាវ

ដោយផ្អែកលើការពិនិត្យឡើងវិញនៃការរំលឹកទ្រឹស្តីក្នុងការសិក្សានាពេលបច្ចុប្បន្ននេះ ដើម្បីយល់ដឹងពីការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព ស្របពេលដែលការយល់ដឹងអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋ ហេដ្ឋានរចនាសម្ព័ន្ធកីឡា ភាសាសកលនៃវិស័យកីឡា និងទីផ្សារកីឡាជាអថេរឯករាជ្យ ចំណែកទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព ដើរតួជាអថេរពឹងផ្អែក។



## ២.៥. ករណីខណ្ឌជ្រោយចង្វារអំពីការស្រាវជ្រាវ

### ២.៥.១. ស្ថានភាពទូទៅ

ខណ្ឌជ្រោយចង្វារជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈអនុក្រឹត្យលេខ៥៧៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដោយបំបែកចេញពីខណ្ឌឫស្សីកែវ តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០១៩ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាលដោយកាត់យកផ្ទៃដីមួយផ្នែករបស់ឃុំសំបួរមាសនៃស្រុកមុខកំពូល ខេត្តកណ្តាលមកឱ្យសង្កាត់បាក់ខែង និងសង្កាត់ព្រែកតាសេកនៃខណ្ឌជ្រោយចង្វារនៃរាជធានីភ្នំពេញ។

បច្ចុប្បន្នខណ្ឌជ្រោយចង្វារមានព្រំប្រទល់ផ្នែកខាងជើងជាប់នឹងស្រុកមុខកំពូល ខេត្តកណ្តាល ផ្នែកខាងត្បូងជាប់នឹងខណ្ឌដូនពេញដែលខណ្ឌដោយទន្លេចតុមុខ ផ្នែកខាងលិចជាប់នឹងដូនពេញ ខណ្ឌឫស្សីកែវ ខណ្ឌព្រែកព្នៅដែលខណ្ឌដោយទន្លេសាប និងផ្នែកខាងកើតជាប់នឹងស្រុកខ្សាច់កណ្តាលដែលខណ្ឌដោយទន្លេមេគង្គ និងមានផ្ទៃដីប្រមាណ៩ ៧៩៧,៦៥ ហិកតា ព្រមទាំងមានចំនួន៥សង្កាត់និងមានចំនួន២២ភូមិគឺ៖

- សង្កាត់កោះដាច់មានលេខកូដ ១២១១០១ និងមានភូមិចំនួន៥គឺភូមិចុងកោះ ភូមិនេះ ភូមិល្វា ភូមិក្បាលកោះ និងភូមិកោះដាច់
- សង្កាត់ជ្រោយចង្វារមានលេខកូដ ១២១១០២ និងមានភូមិចំនួន៥គឺភូមិ១ ភូមិ២ ភូមិ៣ ភូមិដើរគរ និងភូមិគៀនឃ្លាំង
- សង្កាត់បាក់ខែងមានលេខកូដ ១២១១០៣ និងមានភូមិចំនួន៣គឺភូមិចំបក់មាស ភូមិក្តីចាស់ និងភូមិបាក់ខែងលើ
- សង្កាត់ព្រែកលៀបមានលេខកូដ ១២១១០៤ និងមានភូមិចំនួន៤គឺភូមិគៀនឃ្លាំង ភូមិព្រែកលៀប ភូមិខ្វរ និងភូមិបាក់ខែង
- សង្កាត់ព្រែកតាសេកមានលេខកូដ ១២១១០៥ និងមានភូមិចំនួន៥គឺភូមិព្រែកតាសេក ភូមិដើមគរ ភូមិព្រែកតារ័ត្ន ភូមិព្រែកតាគង់ និងភូមិព្រែករាំង។

ក្នុងគោលដៅជានាការគ្រប់គ្រង និងការអភិវឌ្ឍខណ្ឌជ្រោយចង្វារប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខណ្ឌជ្រោយចង្វារក្រោមការគាំទ្របច្ចេកទេស ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំនូវ ប្លង់គោលប្រើប្រាស់ដីខណ្ឌជ្រោយចង្វារចក្ខុវិស័យឆ្នាំ២០៣៥ ដើម្បីជាមូលដ្ឋានក្នុងការគ្រង់គ្រងនិងតម្រង់ទិសការអភិវឌ្ឍដែនដីខណ្ឌជ្រោយចង្វារទាំងមូលឱ្យស្របតាមចក្ខុវិស័យគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។ ( Sarakmonin, 2023 )

### ២.៥.២. ក្របខណ្ឌសេដ្ឋកិច្ចសង្គម និងចំនួនប្រជាពលរដ្ឋ

ដើម្បីកំណត់ចក្ខុវិស័យប្លង់គោលប្រើប្រាស់ដីខណ្ឌជ្រោយចង្វារ ដល់ឆ្នាំ២០៣៥ ក្របខណ្ឌសេដ្ឋកិច្ចសង្គមត្រូវបានសិក្សា វិភាគតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកតាមរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨ និងឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ខណ្ឌជ្រោយចង្វារមានផ្ទៃដីប្រមាណ៩ ៧៩៧.៦៥ហិកតា ប្រជាជននៅឆ្នាំ២០០៨ មានចំនួន៦១ ២១៤នាក់ នៅឆ្នាំ២០១៨ មានចំនួន៦៧ ៨៤៩នាក់ និងនៅឆ្នាំ២០១៩ មានចំនួន៧០ ៦៥៥នាក់ហើយតាមការព្យាករណ៍នៅឆ្នាំ២០៣៥ ប្រជាជននឹងកើនឡើងដល់៩១ ១៧៧នាក់ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ទីតាំងខណ្ឌជ្រោយចង្វារមានសក្តានុពលផ្នែកពាណិកម្ម សិប្បកម្ម ទេសចរណ៍ ការស្នាក់នៅ និងបំពេញការងារដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ចកើនឡើងឆាប់រហ័ស(Sarakmonin, 2023)។

ខណ្ឌជ្រោយចង្វារមានសក្តានុពលទេសចរណ៍វប្បធម៌ និងធម្មជាតិដែលត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ និងផ្សព្វផ្សាយ ដើម្បីទាក់ទាញទេសចរមកទស្សនា និងរៀបចំយន្តការគ្រប់គ្រង និងអភិវឌ្ឍនៅនឹងកន្លែងក្នុងនោះការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ជូនប្រជាជនមូលដ្ឋានគឺជាអាទិភាព(Sarakmonin, 2023)។

### ២.៥.៣. មុខរបរភាគច្រើន

ជាមួយគ្នានេះការបែងចែកកម្លាំងពលកម្ម តាមវិស័យសេដ្ឋកិច្ចសម្រាប់ខណ្ឌជ្រោយចង្វារនៅឆ្នាំ២០០៨ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន៥ ៧៥៦នាក់ ស្មើនឹង៥៤,៩% ហើយរំពឹងថានៅឆ្នាំ២០៣៥ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងថយចុះមកត្រឹមចំនួន៣ ៣៧១នាក់ស្មើនឹង១១,០% វិស័យឧស្សាហកម្មនឹងកើនឡើងដល់ចំនួន១៣ ៧៩០នាក់ស្មើនឹង៤៥,០% និងវិស័យសេវាកម្មនឹងកើនឡើងដល់ចំនួន១៣ ៤៨៤នាក់ស្មើនឹង៤៤,០%(Sarakmonin, 2023)។

### ២.៥.៤. អភិវឌ្ឍខណ្ឌឆ្លាតវៃ ចីរភាព និងបរិយាបន្ន

ដើម្បីលើកកម្ពស់ដល់គុណភាព រស់នៅប្រកបដោយភាពងាយស្រួលក្នុងការទំនាក់-ទំនង និងសន្សំសំចៃឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ននិងអនាគត ប្លង់គោលប្រើប្រាស់ដីខណ្ឌជ្រោយចង្វារចក្ខុវិស័យឆ្នាំ២០៣៥ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍឆ្លាតវៃតាមរយៈការគិតគូរ និងបំពាក់នូវបរិក្ខារនិងសេវាកម្មសម្រាប់ខណ្ឌឆ្លាតវៃ។ ក្នុងនោះមានហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រឹងនិងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើវិស័យវប្បធម៌ សាសនា សេដ្ឋកិច្ច សង្គម ទេសចរណ៍ ពាណិជ្ជកម្ម និងបរិស្ថានក្នុងខណ្ឌជ្រោយចង្វារ។ ហេដ្ឋារចនាសម្ព័ន្ធសង្គម បានជំរុញ ស្តារ និងរៀបចំលម្អសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និង

សាសនាដល់មនុស្សគ្រប់វ័យរួមមានកុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចំណាស់ និងជនពិការឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌។ ហេដ្ឋារចនាសម្ព័ន្ធសង្គម បានរៀបចំឱ្យមានចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បង្គន់អនាម័យ និងបរិក្ខារសម្រាប់សាធារណជន និងជនពិការដើម្បីជានាសោភ័ណភាពសាធារណៈ និងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់សាធារណជននិងជនពិការ(Sarakmonin, 2023)។

តំបន់លម្ហសាធារណៈ និងផ្ទៃបៃតងសំដៅតំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ តំបន់លម្ហសាធារណៈ និងផ្ទៃបៃតងមានទីតាំងនៅតាមបណ្តោយដីចំណីទន្លេមេគង្គ ដីចំណីទន្លេសាប ដីចំណីព្រែក ដីចំណីបឹងត្រារ ផ្នែកខ្លះក្នុងសង្កាត់ជ្រោយចង្វារ សង្កាត់បាក់ខែង និងសង្កាត់ព្រែកលៀបមានផ្ទៃដីប្រមាណ៤៩,៩៥ហិកតាស្មើនឹង០,៧៣% នៃផ្ទៃដីអាចសាងសងបាន។ ជំរុញរៀបចំនិងអភិវឌ្ឍសួនសាធារណៈ និងសួនក្នុងតំបន់លំនៅឋានបន្ថែមឱ្យបានយ៉ាងតិច១០% នៃផ្ទៃដីអាចសាងសង់បាននៅឆ្នាំ២០៣៥(Sarakmonin, 2023)។

## ២.៦.ការសន្និដ្ឋាន

ដូចច្នេះហើយការសិក្សារបស់ខ្ញុំគឺធ្វើឡើងដើម្បីបំពេញបន្ថែមលើទ្រឹស្តីខាងលើក្នុងការរួមចំណែកផ្តល់ជាចំណេះដឹងស្តីពីការចូលរួមរបស់វិស័យកីឡាសហគមន៍ក្នុងសហគមន៍។ ដើម្បីបំពេញចន្លោះនៅក្នុងទ្រឹស្តី ការសិក្សារបស់ខ្ញុំមានគោលបំណងស្វែងយល់ពីទម្រង់ និងការលើកទឹកចិត្តនៃការចូលរួមរបស់វិស័យកីឡាសហគមន៍ក្នុងសហគមន៍និងហេតុផលដែលវិស័យកីឡាសហគមន៍ក្នុងសហគមន៍។ ការសិក្សានេះបានរួមបញ្ចូលគ្នានូវក្របខ័ណ្ឌចូលរួមរបស់ស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងអប់រំ យុវជន និងកីឡា និងCambodia Olympic ដើម្បីស្វែងយល់អំពីការចូលរួមពីបប្រជាពលរដ្ឋ សហគមន៍ និងផ្នែកពាក់ព័ន្ធ។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យដើម្បីបង្កើតចំណេះដឹងនឹងត្រូវបានពិពណ៌នានៅក្នុងជំពូកបន្ទាប់។

# ជំពូកទី៣
# វិធីសាស្ត្រក្នុងការស្រាវជ្រាវ

## សេចក្តីផ្តើម

គោលបំណងនៃជំពូកនៃ គឺដើម្បីពន្យល់អំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការសិក្សានាពេលបច្ចុប្បន្ន។ ជំពូកនេះមានចំពោះគោលបំណងក្នុងការចែកចេញជា៥ផ្នែកធំៗរួមមាន ផ្នែកទី១ ពន្យល់អំពីប្រភេទនៃការវាយតម្លៃទៅលើប្រភេទនៃការសិក្សាស្រាវជ្រាវ ផ្នែកទី២ ទី៣ និង ទី៤ ផ្តល់អំពីទំហំគំរូ ប្រភេទ និងធនធាន ប្រមូលទិន្នន័យ និងបង្ហាញពីឧបករណ៍សម្រាប់ស្រង់ស្ថិតិ និងវិភាគទិន្នន័យដែលប្រមូលបាន ហើយចុងបញ្ចប់នៃជំពូកនេះគឺជាការសន្និដ្ឋាន។

## ៣.១.ប្រភេទនៃការវិភាគទិន្នន័យ

ប្រភេទនៃការវិភាគទិន្នន័យដែលបានធ្វើឡើងនៅក្នុងការសិក្សា គឺជាបរិមាណនៅក្នុងធម្មជាតិ ហើយការវិភាគលើការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍នៅ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព ត្រូវបានអនុវត្តតាមលក្ខណៈបរិមាណវិស័យ។ ជាមួយគ្នានេះដែរ ក្នុងការសិក្សាស្រាវជ្រាវទាំងអស់ត្រូវប្រើប្រាស់ទិន្នន័យបែបគុណភាព និងបរិមាណឬយើងស្គាល់ថា ជាការវិភាគទិន្នន័យបែប Qualitative research និង Quantitative research។ ដោយផ្អែកលើទ្រឹស្តី និងប្រភេទនៃការវិភាគទិន្នន័យស្របតាមសិក្សាផ្សេងៗទៀតដែលបានធ្វើការសិក្សាស្រាវជ្រាវលើទំនាក់ទំនងនៃការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ភាគច្រើនគេប្រើប្រាស់ ការវិភាគតាមបែបបរិមាណវិស័យ ឬ Qualitative research ដែលការវិភាគនេះនឹងផ្អែកលើលទ្ធផលដែលទទួលបានមកពីការសម្ភាសន ៦ដោយប្រើជាកម្រងសំណួរប្រភេទខ្លីៗ បែបយល់ស្រប ឬមិនយល់ស្របនេះបើយោងតាមការសិក្សាស្រាវជ្រាវមួយដែលបង្ហាញពី ការរៀបចំបទសម្ភាសន៍ជាក្រុម ឬជាបុគ្គល ដើម្បីទទួលបានមតិយោបល់ទៅលើអាប្បកិរិយា បទពិសោធន៍ ការវាយតម្លៃទៅលើអត្តចរិតរបស់អ្នកសម្ភាសន៍ដើម្បីទទួលបានលទ្ធផលពិតប្រាកដជាក់ស្តែង (Rowley, 2012)។ យោងតាមការស្រាវជ្រាវកន្លងមកបានបង្ហាញឱ្យឃើញពីភាព ពាក់ព័ន្ធគ្នារវាងអ្នកស្រាវជ្រាវមុន និងប្រធានបទមួយនេះ ហេតុដូចនេះយើងបានជ្រើសរើសយកការ វិភាគទិន្នន័យតាមបែបបរិមាណវិស័យ ដើម្បីតម្លៃលើការយល់ឃើញប្រជាពលរដ្ឋពាក់ព័ន្ធទៅនឹង ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ ត្រូវបានអនុវត្តតាមលក្ខណៈបរិមាណវិស័យ។ ជាពិសេសបន្ទាប់ពីការរៀបចំកម្រងសំណួរសម្រាប់សម្ភាសន៍ យើងនឹងធ្វើការសិក្សាទៅលើទំនាក់ទំនងរវាងកម្រងសំណួរនីមួយៗ ដើម្បីឱ្យដឹងថាមានភាពពាក់ព័ន្ធគ្នាប៉ុន្មានភាគរយ ហើយតើកម្រងសំណួរដែលបានសិក្សានោះអាចគ្របដណ្តប់អ្វីដែលយើងបានវិភាគដែរឬទេ ដោយបានពិចារណាលើកត្តាពេលវេលា និងការចូលរួមសហការឆ្លើយតបរបស់ប្រជាពលរដ្ឋ ព្រមទាំងមានចំនួនអ្នកឆ្លើយតបខ្ពស់ ដូចនេះវិធីសាស្ត្រនៃការស្រាវជ្រាវ

គឺសមស្របសម្រាប់ការសិក្សាជាងគេ ហើយវិធីសាស្រ្តដែលបានរចនាឡើងដើម្បីធ្វើការវាស់វែង និងសាកល្បងទិន្នន័យដែលមានពីមុនមកនោះគឺមានការទាមទារចំនួនអ្នកឆ្លើយតបច្រើន។

## ៣.២.ទំហំ និងបច្ចេកទេសនៃការជ្រើសរើសទិន្នន័យ

ការប្រមូលសំណាក និងប៉ានិគំរូគឺយើងជ្រើសរើសតែប្រជាពលរដ្ឋមួយចំនួនដែលបានកំណត់ថាពួកគាត់កំពុងរស់នៅក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ហើយការវិភាគនេះគឺត្រូវបានផ្តោតសំខាន់ទៅលើកត្តាកំណត់នៃការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព នៅក្នុងខណ្ឌផ្ទាល់។ ក្នុងការគណនានេះ ការសិក្សាត្រូវស្គាល់កម្រិតជឿជាក់ក្នុងការគណនាដើម្បីទទួលបានសំណាកពិតប្រាកដ។ ក្នុងករណីការសិក្សានេះ ត្រូវបានបញ្ជាក់ជាភាគរយ និងតំណាងឱ្យចំនួនភាគរយពិតនៃចំនួនសាកលភាព (Population) ដែលនឹងជ្រើសរើសចម្លើយស្ថិតនៅក្នុងគម្លាតនៃភាពជឿជាក់។ នៅពេលដែលកម្រិតជឿជាក់ ៩៥% មានន័យថាលទ្ធផលនៃគណនាទំហំសំណាកអាចលម្អៀងនូវកម្រិត ៥%។ បើសិនជាកម្រិតជឿជាក់ ៩៩% មានន័យថាលទ្ធផលនៃការគណនាទំហំសំណាកអាចលម្អៀងនូវកម្រិត ១%។ សិក្សាបច្ចុប្បន្ននេះ ការគណនារកទំហំសំណាក ត្រូវបានប្រើប្រាស់ក្នុងកម្រិតលម្អៀងនូវកម្រិត ៥ភាគរយ ដោយផ្អែកតាមរយៈរូបមន្តរបស់យ៉ាសម៉ាន (Yamane 1967) សម្រាប់គណនារកទំហំសំណាកដោយផ្អែកលើចំនួនសកលភាពប្រជាពលរដ្ឋសរុបនៅក្នុងខណ្ឌចំនួន ១៥៩,០០០នាក់ រូបមន្តមានដូចតទៅ $n=\frac{N}{1+N(e)^2}=$ ដែលnជាទំហំសំណា N ជាចំនួនប្រជាពលរដ្ឋ e ជាកម្រិតលម្អៀង ៥%។ ដោយចំនួនប្រជាពលរដ្ឋនៅក្នុងខណ្ឌសរុបមាន១៥៩,០០០ នាក់ ដូច្នេះទំហំសំណាក នៅក្នុងបរិបទធម្មតានៃធម្មតានៃការសិក្សាបែបចិត្តសាស្រ្ត ដែលទាក់ទងនឹងការអង្កេតដែលពាក់ព័ន្ធនឹងបញ្ហាដូចជា ការធ្វើតេស្តសមត្ថភាព វង្វាស់អាកប្បកិរិយា ឬបុគ្គលិកលក្ខណៈជាដើម ការសិក្សាអាចកំណត់បានដូចតទៅ៖ បើទំហំសំណាក (n)= ១០០ មានន័យថា "គ្រប់គ្រាន់"។ ប្រសិនបើទំហំសំណាកមានចំនួន (n) ២០០ ទទួលបានកម្រិត"ល្អ" និងក្នុងករណីបើគណនាឃើញ ទំហំសំណាក (n)មានចំនួន ចាប់ពី៤០០ឡើងទៅគឺ"អស្ចារ្យ"។ សំគាល់ កម្រិតនៃការគណនានៃច្បាប់នេះគឺ យក ៥ភាគរយ (Rules of Thumb for Minimum Sample Size for Multiple Regression, n.d.)។ ដូច្នេះសម្រាប់ទំហំសំណាកនៃការសិក្សាបច្ចុប្ប ៣៧៨នាក់ ជាចំនួនដែលទទួលបានកម្រិត"ល្អប្រពៃ" ហើយសម្រាប់ការសិក្សាប្រមូលទិន្នន័យ។

អ្នកស្រាវជ្រាវបានប្រើ Google Form ដើម្បីបង្កើត និងចែកចាយការស្ទង់មតិតាមអ៊ីនធឺណិតតាមរយៈវេទិកាទំនាក់ទំនង ទៅកាន់មនុស្សទាំងអស់ ៣៧៨ នាក់ ដែលចាប់អារម្មណ៍លើការចូលរួមចំណែករបស់វិស័យកីឡាដែលបានយល់ព្រមចូលរួមក្នុងការសិក្សានេះ។ អ្នកស្រាវជ្រាវបានអញ្ជើញពួកគេឱ្យបំពេញការស្ទង់មតិដោយធ្វើតំណ និងការណែនាំខ្លីៗអំពីការសិក្សា។ អ្នកស្រាវជ្រាវក៏បានលើកទឹកចិត្តពួកគេឱ្យចែករំលែកការស្ទង់មតិជាមួយអតិថិជនផ្សេងទៀត ដែលជាផ្នែកនៃប្រជាជនគោលដៅផងដែរ។ ទំហំគំរូនេះត្រូវបានផ្អែកលើរឹមនៃកំហុស ៥% ដែលជាកម្រិតសមហេតុផលនៃភាពជាក់លាក់សម្រាប់ការស្រាវជ្រាវសង្គម។ ទំហំគំរូក៏អាចធ្វើទៅបាន និងជាក់ស្តែ

ងផងដែរ ដោយផ្តល់ពេលវេលា និងធនធានដែលមានសម្រាប់ការសិក្សា។ លើសពីនេះទៅទៀត ទំហំគំរូគឺគ្រប់គ្រាន់សម្រាប់ធ្វើការវិភាគស្ថិតិដោយប្រើ SPSS កំណែ ២៧ ព្រោះវាបំពេញតាមតម្រូវការអប្បបរមានៃការសង្កេតយ៉ាងហោចណាស់ ១០ ដងច្រើនជាងអថេរ។

## ៣.៣.ប្រភពទិន្នន័យ

ដោយសារប្រធានបទទាក់ទងនឹងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ តើបយើងធ្វើការប្រើប្រាស់ទិន្នន័យចម្បង(Primary Data) ដែលជាទិន្នន័យបានតាមរយៈការសម្ភាសន៍ជាមួយអ្នកអនុវត្តលើវិស័យ អ្នកមានបទពិសោធន៍រៀបចំ ប្រជាពលរដ្ឋក្នុងសហគមន៍ និងអង្គភាពពាក់ព័ន្ធចំនួន៣៧៨នាក់ ដែលកំពុងរស់នៅក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញបច្ចុប្បន្ននេះ។ ទិន្នន័យដែលប្រមូលបានគឺទទួលបានជាលក្ខណៈការស្ទង់មតិដោយមានជាសំណួរបេកស្រាយ សំណួរចំណាប់អារម្មណ៍ និងសំណួរQCMផងដែរ។

ហើយសម្រាប់ការប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំ(Secondary Data) គឺជាទិន្នន័យមួយដែលយើងអាចប្រមូលបានពីឯកសារគោលនយោបាយអនុវត្តន៍ការងាររបស់គ្រប់វិស័យពាក់ព័ន្ធ ប្រមូលទិន្នន័យដែលទទួលបានពីគេហទំព័រ ក្នុងបណ្តាញសង្គម តាមវេបសាយ និងប្រព័ន្ធអ៊ិនធឺណេតដែលពាក់ព័ន្ធនឹងប្រធានបទ។

## ៣.៤.ឧបករណ៍វិភាគទិន្នន័យ

ដោយសារកត្តាពេលវេលានិងភាពចាំបាច់ព្រមទាំងការជឿជាក់លើភាពច្បាស់លាស់នៃទិន្នន័យ នាងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកការស្រាវជ្រាវតាមរយៈកម្រងសំណួរដែលរៀបចំនៅក្នុង Google Form ដោយកំណត់យកអ្នកពាក់ព័ន្ធលើវិស័យនិងអ្នកដែលរស់នៅតំបន់ពាក់ព័ន្ធផ្ទាល់ដើម្បីចូលរួមផ្តល់មតិ។ ការសិក្សាស្រាវជ្រាវនៃទិន្នន័យដែលទទួលបាន ត្រូវបញ្ចូលទៅក្នុងកម្មវិធី SPSS និងវិភាគដោយប្រើស្ថិតិពណ៌នា។ សម្រាប់លទ្ធផលនៃគំហើញ មានឧបករណ៍ស្ថិតិត្រូវបានប្រើសម្រាប់វិភាគទិន្នន័យដូចជា៖

- ការវិភាគទី១៖ ការកំណត់យកអត្តសញ្ញាណត្រឹមត្រូវនៃការវិភាគទិន្នន័យដោយ ជំហានដំបូងនៃការស្ទង់មតិគឺផ្តោតលើអាយុភេទមុខរបរ ចំណង់ចំណូលចិត្ត និងការអប់រំនៃអ្នកផ្តល់ទិន្នន័យដោយប្រើឧបករណ៍ Frequency, Percent, Table, និង Graph។
- ការវិភាគទី២៖ ចំណុចបន្ទាប់នៃការស្ទង់មតិគឺផ្តោតលើការវាយតម្លៃលើប្រសិទ្ធភាពនៃទិន្នន័យដែលទទួលបាននៃការចូលរួមរបស់វិស័យកីឡា និង ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព ដោយប្រើឧបករណ៍ Weight Arithmetic Mean សម្រាប់វិភាគទិន្នន័យ។
- ការវិភាគទី៣៖ ដោយប្រើឧបករណ៍ពហុរីហ្គ្រេសិនសម្រាប់វាយតម្លៃពីការលើកកម្ពស់

នៃការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ទៅលើទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

## ៣.៥.វិធីសាស្ត្រនៃការវិភាគទិន្នន័យ

ដើម្បីឆ្លើយតបទៅតាមការរកឃើញនៃចំនួនសំណាកដែលបានជ្រើស យើងបានធ្វើការបោះពុម្ពកម្រងសំណួរយកទៅសម្ភាសន៍ប្រជាពលរដ្ឋចំនួន ៣៧៨នាក់ ដែលរស់នៅក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីឆ្លើយតប នុងទុករយៈពេលជូនពួកគាត់ធ្វើការសម្រេចចិត្ត ដោយឱ្យពេលវេលាសមល្មមក្នុងការពិចារណាឆ្លើយតប ហើយអាចឱ្យពួកគាត់មានឆន្ទៈក្នុងការឆ្លើយសំណួរជូន និងធ្វើការពន្យល់បន្ថែមដើម្បីឱ្យអ្នកឆ្លើយនូវកម្រងសំណួរទាំងអស់អាចយល់កាន់តែច្បាស់អំពីសំណួរដែលបានរៀបចំឡើង និងងាយស្រួលក្នុងការឆ្លើយ។

បន្ទាប់ពីប្រមូលទិន្នន័យបឋមរួចដែលបានមកពីការសម្ភាសន៍ចេញពីប្រជាពលរដ្ឋផ្ទាល់ដែលរស់នៅក្នុងខណ្ឌជ្រោយចង្វារ និងបានរៀបចំបញ្ចូលទិន្នន័យក្នុងកម្មវិធីSPSSនៅក្នុងកុំព្យូទ័រដើម្បីបញ្ជាក់ឱ្យបានច្បាស់ថារង្វាស់ដែលបានប្រើតាមអថេរនីមួយៗមានភាពបន្សុីគ្នាទៅនឹងឧបករណ៍ស្ថិតិដែលបានគ្រោងទុកឬបើអាចខុសឆ្គងពាក្យពេចន៍ខ្លឹមសារនៃសំណួរណាមួយដែលងាយនឹងមានការកែតម្រូវចាំបាច់ជាមុន ទើបសម្រេចចិត្តប្រមូលទិន្នន័យតាមទំហំសំណាកពិតប្រាកដដែលត្រូវអនុវត្ត។ ចំណុចសំខាន់លើការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រនៃការបង្កើនឱកាស និងចំណូលនៃសេដ្ឋកិច្ចជាតិតាមរយៈការជំរុញឱកាសសហគមន៍ដោយតាមរយៈសកម្មភាពកីឡា។ ដើម្បីឱ្យការស្រាវជ្រាវនេះកាន់តែច្បាស់យើងត្រូវកំណត់អថេរ ចំណុចណាខ្លះជាអថេរឯករាជ្យ(IV) ចំណុចណាខ្លះជាអថេរមិនឯករាជ្យ(DV)។

## ៣.៦.សេចក្តីសន្និដ្ឋាន

ក្នុងជំពូកនេះ យើងនិយាយអំពីលទ្ធផលដែលទទួលបានមកពីការស្ទង់មតិដែលយើងបានសិក្សាស្រាវជ្រាវនៃការប្រមូលទិន្នន័យពីប្រជាពលរដ្ឋដែលរស់នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជាពិសេសតំបន់ទេសចរណ៍ និងអ្នកដែលទទួលផលពីវិស័យកីឡាដោយផ្ទាល់ ដើម្បីធ្វើការវិភាគទៅលើភាពពេញចិត្តនៃការចូលរួមរបស់ប្រជាពលរដ្ឋ សិស្ស និស្សិត យុវជន និងអ្នកពាក់ព័ន្ធ ព្រមទាំងលើកកម្ពស់ដើម្បីយកមកធ្វើការបកស្រាយ។

នៅក្នុងការរៀបចំក្នុងជំពូកទី៣ បានបង្ហាញឱ្យយើងឃើញកាន់តែច្បាស់ និងមានភាពងាយស្រួលក្នុងការសម្រេចចិត្តអំពីវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវមានភាពងាយស្រួល និងប្រទាក់ក្រឡាជាមួយគ្នាក្នុងការរៀបចំឯកសារស្រាវជ្រាវជាពិសេសមានភាពងាយស្រួលក្នុងការកំណត់សមត្ថភាពសំណាក ថាតើត្រូវការចំនួនសំណាកប៉ុន្មានដើម្បីការស្រាវជ្រាវមួយនេះ។ ជាក់ស្តែងនៅក្នុងឯកសារនេះយើងនឹងធ្វើការស្រាវជ្រាវតាមការវិភាគជាលក្ខណៈបរិមាណ(Quantitative Research) យើងទំហំសំណាកដែលយើងគណនាមានចំនួន៣៧៨នាក់ ដែលនឹងត្រូវសម្ភាស ប៉ុន្តែសម្រាប់ចំនួន

ប្រជាជនដែលបានផ្តល់បទសម្ភាស៍ជាក់ស្តែងមានតែចំនួន៣៧៨នាក់ប៉ុណ្ណោះ។ ដោយឡែកទិន្នន័យត្រូវបានប្រមូលដោយផ្ទាល់តាមរយៈការសួរសំណួរនិងសម្ភាស៍ប្រជាពលរដ្ឋក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញផ្ទាល់ និងមួយផ្នែកទៀតត្រូវបានប្រមូលពីការសិក្សាស្រាវជ្រាវកន្លងមក ដើម្បីធ្វើការប្រៀបធៀបអំពីភាពត្រឹមត្រូវនៃការសិក្សាស្រាវជ្រាវ ក៏ដូចជាការពីនិត្យលើភាពប្រែប្រួលនៃសេវាកម្ម បន្ទាប់មកទិន្នន័យដែលយើងប្រមូលបានដែលទទួលផលជាក់ស្តែងនិងមួយផ្នែកទៀតត្រូវបានប្រមូលបាន យើងនឹងធ្វើការវិភាគតាមរយៈSPSS។

សូមថ្លែងអំណរគុណសម្រាប់ការចូលរួមសហការ និងយល់ព្រមឆ្លើយតបទៅនឹងសំណួរស្តីពីការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព។ សូមមេត្តាធ្វើដោយស្មោះត្រង់ ពីព្រោះទិន្នន័យនៅក្នុងកម្រងសំណួរនេះដែលត្រូវយកមកវិភាគ លុះត្រាតែជាប្រភេទទិន្នន័យដែលត្រឹមត្រូវនិងគួរទុកចិត្តបាន។

# ជំពូកទី៤
# វិភាគការលើកកម្ពស់នៃការចូលរួមរបស់វិស័យកីឡាទៅលើទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពរបស់សហគមន៍ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

## ៤.១.សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះ ដើម្បីបង្ហាញពីការចូលរួមរបស់ប្រជាពលរដ្ឋ សិស្ស និស្សិត យុវជន និងការលើកកម្ពស់របស់វាទៅលើទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពរបស់សហគមន៍នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ផ្អែកលើទិន្នន័យដែលប្រមូលបានដូចជា៖ ការយល់ដឹងរបស់ប្រជាពលរដ្ឋ ហេដ្ឋានរចនាសម្ព័ន្ធកីឡា ភាសាសកលនៃវិស័យកីឡា និងទីផ្សារកីឡា ត្រូវបានពិចារណាដោយធ្វើជាទិន្នន័យធ្វើជាទិន្នន័យអថេរឯករាជ្យសម្រាប់វិភាគ។ លើសពីនេះ ដើម្បីពិនិត្យមើលទៅលើតួនាទីនៃការចូលរួមរបស់វិស័យកីឡាទៅលើទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពរបស់សហគមន៍ចាត់ទុកជាទិន្នន័យអថេរពឹងផ្អែកសម្រាប់វិភាគ។ ផ្អែកលើទម្រង់នៃការវិភាគខាងលើ ជំពូកនេះបានចែកចេញជាបីផ្នែក៖ ផ្នែកទី១ បរិយាយពីភាពជឿជាក់នៃចំនួនសំណួរតាមក្រុមអថេរនីមួយៗ។ ផ្នែកទី២ ការវិភាគទិន្នន័យ ក្នុងនោះរួមមាន ការវិភាគអត្តសញ្ញាណអ្នកឆ្លើយតប ការវិភាគរកប្រសិទ្ធភាពនៃការអនុវត្តការចូលរួមរបស់ភាគីពាក់ព័ន្ធនិងការវិភាគរកទំនាក់ទំនងរវាងការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ និងផ្នែកចុងក្រោយសេចក្តីសន្និដ្ឋាន។

ការវិភាគកន្លងមកបានបង្ហាញថា គម្រោង និងការផ្តួចផ្តើមគំនិតផ្សេងៗក្នុងការបង្កើត មានភាពចម្រុះយ៉ាងខ្លាំងនៅក្នុងកីឡាវិធីសាស្ត្រក៏ដូចជាលទ្ធផល និងយុទ្ធសាស្ត្រប្រើប្រាស់ជាយុទ្ធសាស្ត្រដែលត្រូវការរយៈពេល និងមានគោលក្នុងក្នុងការផ្តល់នូវការអភិវឌ្ឍចំពោះសហគមន៍និងសង្គមជាតិ។ ទោះជាយ៉ាងណាក៏ដោយ វិស័យកីឡាបានរួមបញ្ចូលគ្នានូវកត្តាជាច្រើនដែលគាំទ្រដល់ភាពជោគជ័យនៃសកម្មភាពដែលបានចូលរួមចំណែករួមមានៈ បរិបទសង្គមវិជ្ជមាន ការបង្កើតភាពជាម្ចាស់ ការផ្លាស់ប្តូរវប្បធម៌ គម្រោងអភិវឌ្ឍន៍ រចនាសម្ព័ន្ធមូលនិធិ ការបង្កើនភាពប្រែប្រួលនៃវប្បធម៌ ការបង្កើនសមត្ថភាពរដ្ឋបាល និងបង្កើនមិត្តភាពរវាងរដ្ឋនិងរដ្ឋ។

ការវិភាគចំពោះប្រធានបទ ធ្វើឡើងតាមរយៈការសម្ភាសអ្នកពាក់ព័ន្ធតាមរយៈការស្ទង់មតិដោយប្រយោលនិងដោយផ្ទាល់ ដោយបានបង្ហាញឱ្យឃើញថាពីលទ្ធផលជារួមនិងរួមបញ្ចូលគ្នានូវកត្តាជោគជ័យសំខាន់ៗមួយចំនួន។

## ៤.២. ភាពជឿជាក់នៃឧបករណ៍ការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើការវិភាគទៅលើលទ្ធផលស្រាវជ្រាវ ដែលបានមកទៅតាមផ្នែកនីមួយៗនៃទម្រង់ស្រាវជ្រាវបែបបរិមាណវិស័យនិងគុណវិស័យ។ សម្រាប់លទ្ធផលស្រាវជ្រាវបែបបរិមាណវិស័យអ្នកស្រាវជ្រាវនឹងប្រើប្រាស់កម្មវិធីកុំព្យូទ័រ(SPSS)ដើម្បីវិភាគលទ្ធផលដែលទទួលបានតាមរយៈកម្រងសំណួរដែលប្រមូលបានពីប្រជាពលរដ្ឋ សិស្ស និស្សិត យុវជន និងភាគីពាក់ព័ន្ធពីការ

កម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៅខណ្ឌជ្រោយចង្វារ។ កិច្ចការសិក្សាស្រាវជ្រាវនេះបានសម្រេចប្រើប្រាស់អាល់ហ្វា Cronbach's Alpha (α) ដើម្បីជារង្វាស់នៃភាពស្ថិតស្ថេរផ្ទៃក្នុងដែលពេញនិយមក្នុងវិស័យចិត្តសាស្ត្រ និងធ្វើតេស្តជាធាតុដែលអាចទុកចិត្តបាននៃកម្រងសំណួរនៅក្នុងឧបការណ៍ស្រាវជ្រាវសម្រាប់ធ្វើការសិក្សាភាពស្ថិតស្ថេរ។ ឧបករណ៍ស្រាវជ្រាវត្រូវគ្រោងឡើងយ៉ាងយកចិត្តទុកដាក់ ដូចជាផ្អែកលើបញ្ហា ស្រាវជ្រាវឧបការណ៍ស្ថិតិដូចជា Nominal Scale និង Interval Scale សុទ្ធតែត្រូវបានកំណត់ជាទម្រង់ សំណួរសម្រាប់អ្នកឆ្លើយតបដោយប្រើប្រាស់៥រង្វាស់សម្រាប់ឆ្លើយតបដូចជា មិនយល់ស្របខ្លាំង មិនយល់ស្រប យល់ស្របខ្លះៗ យល់ស្រប និងយល់ស្របខ្លាំង។ លទ្ធផលនៃការស្រាវជ្រាវនេះបែបគុណវិស័យដែលទទួលបានពីការស្វែងរកមតិចូលរួមរបស់អ្នកពាក់ព័ន្ធនិងអ្នកជំនាញផ្នែកកីឡាលើមតិយោបល់ដែលដូចគ្នាឬស្រដៀងគ្នាដើម្បីទាញសេចក្តីសន្និដ្ឋានរួមមួយ។លទ្ធផលដែលទទួលបានពិការសម្ភាសន៍នឹងទៅបំពេញបន្ថែមលើអ្វីដែលបានរកឃើញតាមរយៈកម្រងសំណួរឱ្យកាន់តែច្បាស់សាស់ពិសេសបានឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរផ្នែកខាងលើឱ្យកាន់តែស៊ីជម្រៅនិងមានភាពជឿជាក់ខ្ពស់។

បន្ទាប់ពីទទួលបានទិន្នន័យដែលបានប្រមូលរួចហើយ ត្រូវបានវាស់វែងសម្រាប់រកភាពទុកចិត្ត internal Consistency តេស្តលើកម្រងសំណួរ។ ដោយផ្អែកលើលទ្ធផលតេស្តនៃកម្រងសំណួរនីមួយៗត្រូវមានលទ្ធផលធំជាង៧០%ទើបអាចយកទិន្នន័យទៅវិភាគបាន។ ដើម្បីទទួលបានលទ្ធផល សមស្របតាមផ្លូវដែលការសិក្សាស្រាវជ្រាវចង់បាន យើងគណនា Cronbach's Alpha តាមរូបមន្ត $\propto = \frac{k}{k-1}[1 - \frac{\sum SD^2{}_i}{SD^2{}_i}]$

តារាង៖ លទ្ធផលនៃលលទ្ធផលតេស្តកម្រងសំណួរលើប្រធានបទ៖

| ល.រ | អថេរ (Variables) | ចំនួនអ្នកឆ្លើយតប | Item | a>0.៧0 | ការបកស្រាយ |
|---|---|---|---|---|---|
| ១ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ៣៧៨ | ៤ | 0.៦៥៨ | ទទួលយក |
| ២ | ហេដ្ឋានរចនាសម្ព័ន្ធកីឡា | ៣៧៨ | ៤ | 0.៧៣៥ | ល្អ |
| ៣ | ភាសាសកលនៃវិស័យកីឡា | ៣៧៨ | ៤ | 0.៧២៧ | ល្អ |
| ៤ | ទីផ្សារកីឡា | ៣៧៨ | ៥ | 0.៧៤២ | ល្អ |
| ៥ | ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព | ៣៧៨ | ៤ | 0.៨១៧ | ល្អប្រសើរ |

## ៤.៣. ការវិភាគទិន្នន័យ

ក្នុងផ្នែកនេះ ជាផ្នែកដែលទិន្នន័យត្រូវយកមកវិភាគដើម្បីទាញយកលទ្ធផលសម្រាប់បកស្រាយ។ ការវិភាគទិន្នន័យរួមមានប្រភេទដូចជា៖ ព័ត៌មានទូទៅរបស់អ្នកផ្តល់បទសម្ភាស៍,ការវាយតម្លៃទ្រសិទ្ធភាពនៃការអនុវត្តការចូលរួមរបស់ប្រជាពលរដ្ឋនិងទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពរបស់សហគមន៍នៅខណ្ឌជ្រោយចង្វារ និងចុងក្រោយវិភាគលើការលើកកម្ពស់នៃការចូលរួម

របស់វិស័យកីឡាទៅលើទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពរបស់សហគមន៍ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

### ៤.៣.១.ពត៌មានទូទៅរបស់អ្នកផ្តល់ទិន្នន័យ

ការសម្រង់មតិយោបល់ដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះ យើងមានចំនួនអ្នកចូលរួមផ្តល់ចម្លើយពីកម្រងសំណួរនៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ សរុបចំនួន ៣៧៨នាក់។ ជាមួយគ្នានេះដែរ បើយោងតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍ប្រជាពលរដ្ឋចំនួន ៣៧៨នាក់ យើងទទួលបានការបង្ហាញឱ្យឃើញពីកម្រិតនៃភាពជឿជាក់របស់កកម្រងសំណួរតាមរយៈការវិភាគរបស់ឧបករណ៍វិភាគSPSS ២៧បានបង្ហាញឱ្យឃើញពីលទ្ធផលនៃសម្មតិកម្មទាំង៤ គឺភាពជឿជាក់អាល់ហ្វាសម្រាប់សម្មតិកម្មនីមួយៗដូចបានបង្ហាញក្នុងតារាងខាងក្រោម៖

### ៤.៣.១.១. ភេទរបស់អ្នកផ្តល់បទសម្ភាសន៍

តាមរយៈការស្ទង់មតិអ្នកដែលចូលរួមផ្តល់បទសម្ភាសភាគច្រើនមានភេទជាស្រ្តីច្រើន ក្នុងការចូលរួមចំលែកយ៉ាងសកម្មក្នុងការចូលរួមកក្នុងការអភិវឌ្ឍសង្គមជាតិ។ សម្រាប់ភាគរយនៃការចូលរួមអ្នកមានភេទជាស្រ្តីមានចំនួន៥១.៦ភាគរយ បុរសមានចំនួន៤៨.៤ភាគរយ។

| | Frequency | Percent |
|---|---|---|
| ស្រ្តី | ១៩៥ | ៥១.៦% |
| បុរស | ១៨៣ | ៤៨.៤% |
| សរុប | ៣៧៨ | ១០០% |

### ៤.៣.១.២. អាយុរបស់អ្នកផ្តល់បទសម្ភាសន៍

តាមរយៈការស្ទង់មតិអ្នកដែលចូលរួមផ្តល់បទសម្ភាសភាគច្រើនមានអាយុចាប់ពី៤៥រហូតដល់៥៤ឆ្នាំដែលជាវ័យក្នុងការចូលរួមចំលែកយ៉ាងសកម្មក្នុងការចូលរួមកក្នុងការអភិវឌ្ឍសង្គមជាតិ។ សម្រាប់ភាគរយនៃការចូលរួមអ្នកមានអាយុចន្លោះចាប់ពី៤៥រហូតដល់៥៤ឆ្នាំមានចំនួន៤២.៤ភាគរយ អ្នកមានអាយុចន្លោះចាប់ពី២៥រហូតដល់៣៤ឆ្នាំមានចំនួន៣៩.១ភាគរយ ៣៥រហូតដល់៤៤ឆ្នាំមានចំនួន១៣.៦ភាគរយ ១៨រហូតដល់២៤ឆ្នាំមានចំនួន៧.៥ភាគរយ និង៥៥ ឬខ្ពស់ជាងនេះមានចំនួន១ភាគរយ។

| | Frequency | Percent |
|---|---|---|
| ២៥-៣៤ | ១២១ | ៣៩.១% |
| ៣៥-៤៤ | ៧៦ | ១៣.៦% |
| ៤៥-៥៤ | ១៣៨ | ៤២.៤% |
| ១៨-២៤ | ៥១ | ៧.៥% |
| ៥៥ ឬខ្ពស់ជាងនេះ | ២ | ១% |
| សរុប | ៣៧៨ | ១០០% |

### ៤.៣.១.៣. កម្រិតវប្បធម៌របស់អ្នកផ្តល់បទសម្ភាសន៍

អ្នកផ្តល់បទមានកម្រិតនៃការសិក្សានឹងចំណេះដឹងរួមមាន កម្រិតបរិញ្ញាបត្រមានចំនួន៧១.៤ភាគរយ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់២៨.៦ភាគរយ បឋមសិក្សាមានចំនួន០ភាគរយ អនុវិទ្យាល័យមានចំនួន០ភាគរយ វិទ្យាល័យមានចំនួន០ភាគរយ។

| | Frequency | Percent |
|---|---|---|
| បរិញ្ញាបត្រជាន់ខ្ពស់ | ១០៨ | ២៨.៦% |
| បរិញ្ញាបត្រ | ២៧០ | ៧១.៤% |
| បឋមសិក្សា | ០ | ០% |
| អនុវិទ្យាល័យ | ០ | ០% |
| វិទ្យាល័យ | ០ | ០% |
| សរុប | ៣៧៨ | ១០០% |

### ៤.៣.១.៤. មុខរបរបច្ចុប្បន្នរបស់អ្នកផ្តល់បទសម្ភាសន៍

តាមការចូលរួមរបស់អ្នកផ្តល់បទសម្ភាសន៍អ្នកដែលមានមុខរបរបច្ចុប្បន្ន អ្នកផ្តល់បទសម្ភាសន៍យើងទទួលបានលទ្ធផលដូចជា បុគ្គលិកស្ថាប័ន ឬក្រុមហ៊ុនមានចំនួន៨០.២ភាគរយ សិស្សនិស្សិតចំនួន១០.៣ភាគរយ ម្ចាស់អាជីវកម្មមានចំនួន៩.៥ភាគរយ និងអ្នកចូលនិវត្តន៍មានចំនួន០ភាគរយ ។

| | Frequency | Percent |
|---|---|---|
| បុគ្គលិកស្ថាប័ន ឬក្រុមហ៊ុន | ៣០៣ | ៨០.២% |
| ម្ចាស់អាជីវកម្ម | ៣៦ | ៩.៥% |
| សិស្សនិស្សិត | ៣៩ | ១០.៣% |
| ចូលនិវត្តន៍ | ០ | ០% |
| សរុប | ៣៧៨ | ១០០% |

### ៤.៣.១.៥. អាស័យដ្ឋានរបស់អ្នកផ្តល់បទសម្ភាសន៍

អាស័យដ្ឋានរបស់អ្នកផ្តល់បទសម្ភាសន៍ តាមការចូលរួមរបស់អ្នកផ្តល់បទសម្ភាសន៍ដែលមាននៅទីតាំងណាដែលច្រើនជាងគេរបស់ អ្នកផ្តល់បទសម្ភាសន៍យើងទទួលបានលទ្ធផល ដូចជា សង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក ២៣.៨ភាគរយ សង្កាត់បាក់ខែងមានចំនួន ២៣.៥ភាគរយ សង្កាត់កោះដាច់មានចំនួន៥ភាគរយ

| | Frequency | Percent |
|---|---|---|
| សង្កាត់បាក់ខែង | ៨៩ | ២៣.៥% |
| សង្កាត់ជ្រោយចង្វារ | ៩០ | ២៣.៨% |
| សង្កាត់កោះដាច់ | ១៩ | ៥% |
| សង្កាត់ព្រែកលៀប | ៩០ | ២៣.៨% |
| សង្កាត់ព្រែកតាសេក | ៩០ | ២៣.៨% |
| សរុប | ៣៧៨ | ១០០% |

## ៤.៤. ការវាយតម្លៃប្រសិទ្ធភាព

តាមវិភាគចំពោះប្រសិទ្ធភាពនៃកម្រងសំណួរស្រាវជ្រាវយើងអាច សន្និដ្ឋានបានថាកម្រងសំណួរស្រាវជ្រាវមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ដោយផ្អែកតាមរយៈចំណុចមួយចំនួននៃកម្រងសំណួរស្រាវជ្រាវដូចជា ចំណេះដឹងនៃព្រឹត្តការណ៍កីឡា អត្ថប្រយោជន៍ និងសារៈសំខាន់នៃវិស័យកីឡា ការវិភាគចំពោះមតិចូលរួមថាវិស័យកីឡាពិតជាបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍ពិតមែន វិស័យកីឡាជាកត្តាមួយដែលពិតជាបានជួយបង្កើនប្រាក់ចំណូលនិងមុខរបរជូនប្រជាពលរដ្ឋពិតប្រាកដមែន សារៈសំខាន់នៃការចូលរួមលើកកម្ពស់លើវិស័យកីឡាដើម្បីជំរុញក្នុងការអភិវឌ្ឍជីវភាពសហគមន៍ គោលបំណងនៃការពង្រឹងកីឡា ដំណើរការនៃការរៀបចំផែនការអនុវត្ត និងផ្នែកសំខាន់ៗផ្សេងៗជាច្រើនទៀត។

| អថេរ | N | មធ្យមភាគ | គម្លាតស្តង់ដា | ការបកស្រាយ |
|---|---|---|---|---|
| ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ៣៧៨ | ៤.១៨៨៥ | ០.៤៣៣៩៩ | យល់ស្រប |
| ហេដ្ឋារចនាសម្ព័ន្ធកីឡា | ៣៧៨ | ៤.២៨៥១ | ០.៤៨១៦៩ | យល់ស្រប |
| ភាសាសកលនៃវិស័យកីឡា | ៣៧៨ | ៤.២៥១៣ | ០.៤៩៦០០ | យល់ស្រប |
| ទីផ្សារកីឡា | ៣៧៨ | ៤.២៥៥០ | ០.៤៦៨៨០ | យល់ស្រប |
| ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព | ៣៧៨ | ៤.៣១៤៨ | ០.៥៥២០៩ | យល់ស្រប |

(1.Strongly Disagree, 2. Disagree, 3. Undecided, 4. Agree, 5. Strongly Agree)

## ៤.៥. ការវាយតម្លៃលទ្ធផលនៃការស្រាវជ្រាវ

### ៤.៥.១. Multicollinearity

ការធ្វើតេស្តនេះមានគោលបំណងស្វែងរកទំនាក់ទំនងរវាងអថេរឯករាជ្យនិងអថេរមិនឯករាជ្យជាមួយគ្នានេះការវិភាគនិងបកស្រាយកំណត់យកតម្លៃVIFតូចជាង៥(VIR<5)និង Tolerance ធំជាង ០.២០(Tolerance>0.២០) យោងតាមលោក O'Brien R.M បោះពុម្ពនៅឆ្នាំ ២០០៧។ ដូច្នេះតម្លៃVariance Inflation Factor នៃអថេរឯករាជ្យនីមួយៗនៅក្នុងតារាងខាងលើសុទ្ធតែតូចជាង៥និងតម្លៃTolerance អថេរនីមួយៗក៏សុទ្ធតែធំជាង២០%ទាំងអស់។ ត្រូវសន្និដ្ឋានបានថាអថេរឯករាជ្យទាំង៤( អត្ថប្រយោជន៍ និងសារៈសំខាន់នៃវិស័យកីឡា គោលបំណងនៃការពង្រឹង ដំណើរការនៃការរៀបចំផែនការអនុវត្ត កត្តាចាំបាច់ដែលជាយន្តការពាក់ព័ន្ធ) នីមួយៗមានទំនាក់ទំនងគ្នា។

តាមរយៈការសម្រង់មតិយើងអាចវាយតម្លៃចំពោះលទ្ធផលនៃកិច្ចការស្រាវជ្រាវពិតជាអាចជឿជាក់បានពីភាពជាក់លាក់នៃលទ្ធផលដែលទទួលបានដោយកម្រងសំណួរមួយចំនួនដូចជាភាពជឿជាក់លើគុណតម្លៃនៃវិស័យកីឡានិងការចូលរួមចំណែកសំខាន់ៗដែលអ្នកផ្តល់ការចូលរួមនៃកម្រងសំណួរបានចូលរួម។

| **អថេរពឹងផ្អែក** | R=0.789[a]<br>$R^2$=0.560<br>R-Adjust=0.555 | | F=118.692<br>Sig<0.001[b] | | |
|---|---|---|---|---|---|
| **អថេរឯករាជ្យ** | Regression coneffiicient | t-Value | Sig | Collinearity | |
| | | | | Tolerance | VIF |
| ការយល់ដឹងរបស់ប្រជាពលរដ្ឋ | .303 | 4.474 | .000 | .405 | 2.471 |
| ហេដ្ឋានរចនាសម្ព័ន្ធកីឡា | .167 | 2.632 | .009 | .375 | 2.664 |
| ភាសាសកលនៃវិស័យកីឡា | 1.559 | 19.549 | .000 | .223 | 4.475 |
| ទីផ្សារកីឡា | 1.189 | 13.744 | .000 | .213 | 4.700 |

ដូចនេះតាមតារាងខាងលើតម្លៃVariance Inflation Factors នៃអថេរឯករាជ្យនីមួយៗនៅក្នុងតារាងនេះសុទ្ធតែតូចជាង៥និងតម្លៃTolerance អថេរនីមួយៗសុទ្ធតែធំជាង២០%លើកលែងតែការគោលបំណងនៃការបង្កើនការចូលរួមពង្រឹងវិស័យកីឡាដែលមានតម្លៃVIF4.700<5និងតម្លៃTolerance 0.405<20%។ ដោយត្រូវបានសន្និដ្ឋានថាមានតែគោលបំណងនៃការចូលរួមពង្រឹងវិស័យកីឡាប៉ុណ្ណោះដែលពុំមានទំនាក់ទំនងគ្នា

### ៤.៥.២.ការតេស្តNormal Distribution

ការចែកចាយធម្មតានៅក្នុងក្រាហ្វ ការចែកចាយ( Error reference source not found ) ដែលបង្ហាញពីភាពធម្មតាដោយសូន្យក៏ជាចំណុចកណ្តាលនៃក្រាហ្វ ហើយទិន្នន័យស្ថិតនៅចន្លោះពី-៤ដល់+៤នៃក្រាហ្វមានរាងជាខ្សែរកោងកណ្តឹង។ ដែលនេះបង្ហាញពីលទ្ធផលនៃការចែកចាយទិន្នន័យសម្រាប់ម៉ូដែលសមីការRegression។ ដូចនេះ យើងនេះសន្និដ្ឋានបានថា គំរូនៃអថេរមានភាពគ្រប់គ្រាន់ដើម្បីវិភាគសមីការRegression ( Multiple Regression )។




នៅក្នុងក្រាហ្វិកP-P plot នៃZ-pred. និង Z-resid បានបង្ហាញថា វាមានលក្ខណៈធម្មតាដូចបង្ហាញក្នុង Error Reference soure not found ខាងក្រោម។ ចំពោះចំណុចតូចៗ ត្រូវបានពង្រាយតោងកៀកសន្ទកខ្សែរបន្ទាត់ធម្មតា ដែលមានន័យថាការស្នង់មតិសំណាកទិន្នន័យពីព្រោះគម្លាតទិន្នន័យពីមួយទៅមួយគឺមានភាពប្រទាក់ក្រឡាគ្នា។ (អ័ក្សYជាសស្តង់ដារ)




### ៤.៥.៣.Homoscedasticity Check

ជាលទ្ធផលនៃទិន្នន័យ Homoscedasticity  ពីScatterplot ក្នុង( Error reference source not found  ) ខាងក្រោមបង្ហាញថាគ្រោងគឺនៅជិតនឹងបន្ទាត់ត្រង់ដែលមកពីZ Resid (អ័ក្សYជាស្តង់ដាសំណាល់ Regression) ប្រឆាំងនឹង Z Red (អ័ក្ស X ជាស្តង់ដាកម្រិតតម្លៃព្យាករណ៍)។ ទិន្នន័យត្រូវបានចែកចាយយ៉ាងល្អនៅព័ន្ធជុំវិញអ័ក្សសូន្យនៅចន្លោះរវាងអ័ក្សX និងអ័ក្សY( ចន្លោះពី-2 ដល់+2)។ សរុបមក អថេរឯករាជ្យ( Independent Variable) ទាក់ទងទៅនឹងអថេរពឹងផ្អែក (dependent variable)។


Scatterplot
Dependent Variable: ទីផ្សារបែតងសាធារណៈ និងសុខុមាលភាព
Regression Standardized Residual
4
2
0
-2
-4
-3
-2
-1
0
1
2
Regression Standardized Predicted Value

# ជំពូកទី៥
# យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីធ្លាបៃតងសាធារណៈ ដែលមានស្រាប់ និងថ្មីបន្ថែមទៀតសម្រាប់លើកកម្ពស់វិស័យកីឡាក្នុង ពេលបច្ចុប្បន្ន និងអនាគត នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

## សេចក្តីផ្តើម

គោលបំណងសំខាន់នៃជំពូកនេះគឺដើម្បីបង្ហាញគឺដើម្បីបង្ហាញពីការសិក្សាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីធ្លាបៃតងសាធារណៈដែលមានស្រាប់ និងថ្មីបន្ថែមទៀតសម្រាប់លើកកម្ពស់វិស័យកីឡាក្នុងពេលបច្ចុប្បន្ន និងអនាគត នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ដើម្បីបំពេញនូវគោលបំណងជំពូកនេះត្រូវចែកជា៣ផ្នែកសំខាន់ៗ៖ ផ្នែកទី១ សាវតា ផ្នែកទី២ អត្ថប្រយោជន៍និងការអនុវត្តល្អរបស់វិស័យកីឡា ផ្នែកទី៣ អភិវឌ្ឍទីធ្លាបៃតងសាធារណៈនិងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់លើកកម្ពស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ ផ្នែកទី៤ សេចក្តីសន្និដ្ឋាន។

## ៥.១. សាវតា

តំបន់ខណ្ឌជ្រោយចង្វារ បានធ្វើការវិនិយោគយ៉ាងសកម្មនៅហេដ្ឋានរចនាសម្ព័ន្ធសាធារណៈត្រូវបានជម្រុញស្របទៅតាមផែនការនៃចក្ខុវិស័យរបស់រាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា នៅក្នុងការកែប្រែទីក្រុងភ្នំពេញឱ្យក្លាយទៅជារាជធានីសតវត្សរ៍ទី២១។ ក្នុងនោះចលនាកីឡាជាផ្នែកមួយដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ កីឡាបានជះឥទ្ធិពលគ្រប់ទីកន្លែងជុំវិញពិភពលោកមិនថានៅក្នុងប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍឬប្រទេសក្រោមការអភិវឌ្ឍនោះឡើយ ដែលកីឡាតែងតែជាឱសថក្នុងការបង្កភាពសប្បាយរីករាយ មោទនភាពជាតិ សាមគ្គីភាព មិត្តភាព សន្តិភាពនិងឧត្តមភាពជាតិលើឆាកអន្តរជាតិ ពីសកម្មភាពកីឡានិងព្រឹត្តិការណ៍កីឡានានា (គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា)។

ទន្ទឹមនឹងនេះផងដែរកម្ពុជាធ្លាប់ឆ្លងកាត់សោកនាដកម្មនៃសង្គ្រាមដែលធ្វើឱ្យវិស័យកីឡាក៏ដូចជាវិស័យដទៃទៀតធ្លាក់ចុះក្រោមសូន្យ ហើយតាមរយៈពន្លឺនៃ**សន្តិភាព** ស្ថេរភាពនយោបាយ កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម៧.៧% ក្នុងរយៈពេលពីទស្សវត្សចុងក្រោយ វិស័យកីឡានៅកម្ពុជា បានរីកចម្រើននិងទទួលបានការគាំទ្រពីយុវជននិងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។ ក្នុងបរិការណ៍ប្រជាសាស្ត្រសម្បូរដោយប្រជាពលរដ្ឋវ័យក្មេងជាក្តីសង្ឃឹមនៃកម្លាំងការងារ ជាអនាគតរឹងមាំនៃប្រទេសជាតិ។ កីឡាជាមោទនភាពជាតិ ជាឧត្តមភាពជាតិ និងជាចំណីអាហារបំប៉នថាមពលរាងកាយនិងជាចំណីអារម្មណ៍ ដែលមិនអាចខ្វះបានក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ(Press OCM)។

បច្ចុប្បន្ននេះកីឡាក្លាយជាចលករអភិវឌ្ឍសង្គមក្លាយជាឧស្សាហកម្មកីឡា ធុរកិច្ចកីឡា និងជានយោបាយទ្រទ្រង់សង្គមទាំងក្នុងនិងក្រៅប្រទេស ពិសេសកីឡាក្លាយជាចលនាទ្រទ្រង់សេវាសុខភាពសាធារណៈដ៏មានប្រសិទ្ធភាព ដែលរាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្ពស់ក្នុងការក្នុងការរៀបចំនិងការដាក់ចេញនូវគោលនយោបាយជាតិស្តីពីការអភិវឌ្ឍអប់រំកាយនិងកីឡាដើម្បីជាកត្តាកំណត់ចក្ខុវិស័យជាតិប្រកបដោយសក្តានុពលនិងឧត្តមភាពជាតិក្នុងតំបន់និងក្នុងពិភពលោក(ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងឱកាសពិធីបិទកីឡាជាតិលើកទី៣ ២១/១១/២០២២)។

## ៥.២. អត្ថប្រយោជន៍និងការអនុវត្តល្អរបស់វិស័យកីឡា

ការរៀបចំឡើងនូវព្រឹត្តិការណ៍កីឡានិងសកម្មភាពកីឡាដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យកីឡា វប្បធម៌ ទេសចរណ៍នយោបាយការទូត និងសេដ្ឋកិច្ចសង្គម ក្នុងនោះផងដែរព្រឹត្តការណ៍កីឡាផ្តល់ឱកាសជាច្រើនសម្រាប់ការអភិវឌ្ឍដូចជា(AKP/2023)៖

- ជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម
- កសាងកេរ្តិ៍ឈ្មោះសម្រាប់ជាប្រវត្តិសាស្ត្រ
- ជំរុញទឹកចិត្តស្នេហាជាតិ សាមគ្គីភាព និងការគោរពគ្នាទៅវិញទៅមក
- អាចពង្រឹងស្ពានទំនាក់ទំនងការទូត នយោបាយ សេដ្ឋកិច្ចជាមួយប្រទេសក្នុងតំបន់និងពិភពលោក
- ជាឱកាសក៏កម្រដែលអាចលាងសម្អាតភាពអវិជ្ជមាន អសកម្ម និងបរិស្ថានសង្គម
- ជាការបង្ហាញមួយសម្រាប់បង្ហាញពីការប្រតិបត្តិសមត្ថភាពគុណភាពរបស់អ្នកលេងកីឡាកម្រិតខ្ពស់
- បង្កើនការចូលរួមក្នុងវិស័យកីឡាដែលនាំមកនូវឱកាសក្នុងការដណ្តើមឧត្តមភាពកីឡា
- លើកកម្ពស់មុខមាត់ប្រទេសក្នុងទីផ្សារពាណិជ្ជកម្មពិភពលោក
- កែលម្អហេដ្ឋារចនាសម្ព័ន្ធ(ការអភិវឌ្ឍសេដ្ឋកិច្ច) ការចូលរួមក្នុងវិស័យកីឡានឹងធ្វើឱ្យមានភាពប្រសើរឡើងក្នុងការទាក់ទាញការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ
- ការលើកកម្ពស់សេដ្ឋកិច្ចរយៈពេលវែងវិស័យកីឡាតាមរយៈការរៀបចំព្រឹត្តការណ៍កីឡាធំៗអាចជះឥទ្ធិពលយ៉ាងឆាប់រហ័សនិងមានរយៈពេលវែងដល់សេដ្ឋកិច្ច។ សកម្មភាពវិនិយោគសំខាន់ៗតម្រូវឱ្យមានទាំងមុនពេល កំឡុងពេលនិងពេលបន្ទាប់ពីការរៀបចំដែលបានផ្តល់ឱកាសនិងបង្កើនការងារបានច្រើនជាពិសេសបង្កើនឱកាសជំនួញថ្មីៗក្នុងការវិនិយោគ។

### ៥.២.១. ការអនុវត្តន៍ល្អរបស់កម្ពុជាចំពោះវិស័យកីឡា

ដោយមានការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នវិស័យកីឡាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិដោយក្នុងនោះកម្ពុជា

តែងតែរៀបចំនូវកម្មវិធីនិងព្រឹត្តិការណ៍កីឡាកម្រិតតំបន់កម្រិតថ្នាក់ជាតិ និងថ្នាក់អន្តរជាតិជាពិសេសគឺ៖

- **ព្រឹត្តិការណ៍កីឡាធំៗរួមមានព្រឹត្តការណ៍កីឡាជាតិ** ដែលរៀបចំឡើងរយៈពេល២ឆ្នាំម្តងកម្ពុជាដែលផ្តល់ឱកាសដល់យុវជនសិស្សានុសិស្សមានឱកាសក្នុងការចូលរួមបង្ហាញពីសមត្ថភាពចំណងសាមគ្គីភាពនិងឱកាសបង្ហាញពីសក្តានុពលរបស់យុវជនសិស្សានុសិស្សនិងធនធានមនុស្សរបស់កម្ពុជាទៅកាន់បណ្តាលប្រទេសផ្សេងៗដែលជាចំណុចមួយនៃការទាក់ទាញទេសចរណ៍និងបង្កើនទីផ្សារសេដ្ឋកិច្ចមួយចំនួនចូលមកក្នុងប្រទេសកម្ពុជា។ ក្រោយពីទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិអូឡាំពិក ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងសហព័ន្ធកីឡាជាតិ បានរៀបចំការប្រកួតព្រឹត្តិការណ៍កីឡាជាតិលើកទី៣ និងកីឡាជាតិប៉ារ៉ាហ្គេម ដើម្បីផ្តល់អត្ថប្រយោជន៍ដល់មន្ត្រីបច្ចេកទេស អ្នកស្ម័គ្រចិត្ត កីឡាករ កីឡាការិនី ពិសេសសហព័ន្ធកីឡាជាតិ បានរៀនសូត្រពីការអនុវត្តផ្ទាល់ និងបទពិសោធន៍ល្អៗ ក្នុងការដឹកនាំគ្រប់គ្រង ត្រៀមរៀបចំព្រឹត្តការណ៍កីឡាធំៗនៅកម្ពុជា។ ការរៀបចំព្រឹត្តិការណ៍កីឡាជាតិនេះ ក៏ជាការផ្តល់ឱកាសដល់មន្ត្រីបច្ចេកទេសបានដោះស្រាយបញ្ហានៃដំណើរការប្រកួតពហុកីឡា (Sport Games) កម្រិតជាតិ ដែលមានទម្រង់ប្រហាក់ប្រហែលនឹងកម្រិតអន្តរជាតិផងដែរ។ ព្រឹត្តិការណ៍កីឡាជាតិនេះ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការគ្រប់គ្រងពហុកីឡា ការយល់ដឹងពីរូបមន្តស្តង់ដារគ្រប់គ្រងរួមមួយ ដែលផ្តល់ការយកចិត្តទុកដាក់របស់សសរស្តម្ភទាំង៣ គឺជាការចាំបាច់ ក្នុងនោះរួមមាន ៖ **១**-ការរៀបចំបច្ចេកទេសកីឡា ដែលជាតួនាទីរបស់សហព័ន្ធកីឡាជាតិ។ **២**-ការរៀបចំបដិសណ្ឋារកិច្ចប្រតិភូកីឡាជាមួយនឹងការដឹកជញ្ជូន ហូបចុកស្នាក់នៅ សន្តិសុខសណ្តាប់ធ្នាប់ សុខាភិបាល និងពិធីការកីឡា ។ **៣**-ពិធីបើក-បិទកីឡាផ្សេងៗទៀត។ សសរស្តម្ភធំៗទាំងបីខាងលើនេះបានរៀបចំប្រកបដោយស្តង់ដារជំនាញវិជ្ជាជីវៈកីឡា ជាមួយនឹងកិច្ចសហប្រតិបត្តិការយ៉ាងល្អពីគ្រប់ភាគីពាក់ព័ន្ធ ដោយប្រទាក់ក្រឡាគ្នាបានល្អនោះនឹងជំរុញឱ្យទិវាកីឡាក្លាយជាបុណ្យកីឡាដ៏អធិកអធម ប្រកបដោយកិត្តិយស កិត្យានុភាព និងមោទកភាពសម្រាប់មុខមាត់របស់កម្ពុជា។ «ធម្មនុញ្ញអូឡាំពិកបានលើកឡើងជាគោលការណ៍គ្រឹះ ឱ្យចលនាអូឡាំពិកសហការជាមួយរដ្ឋអំណាចកីឡា ដោយគោរពស្វ័យភាពគ្នាទៅវិញទៅមក ក្នុងគោលដៅរួម គឺការកសាង និងអភិវឌ្ឍន៍វិស័យកីឡាតាមរយៈសកម្មភាពអប់រំកាយ និងកីឡា ដើម្បីមានការយោគយល់គ្នា សាមគ្គីគ្នា មិត្តភាព និងសុខដុមរមនា ដោយមិនប្រកាន់និន្នាការនយោបាយ សាសនា វណ្ណៈឋានៈសង្គមឡើយ»។ កីឡា គឺជាភាសាសកលតែមួយ "Sport is a Universal language" ដែលអាចជាមធ្យោបាយមួយរួមចំណែកដល់ការកសាងពិភពលោកមួយល្អប្រសើរបាន "Sport Build a Better World" ។ មានសន្តិភាពទើបកីឡាអាចមានការអភិវឌ្ឍ និងមាននិរន្តរភាព ដូចបាវចនា SEA Games-ASEAN ឆ្នាំ២០២៣ ចែងថា «កីឡារស់ក្នុងសន្តិភាព»។ កីឡាមិនអាចមានការអភិវឌ្ឍបាន នៅក្នុង

ប្រទេសជាតិមួយដែលមិនមានសន្តិភាពនោះទេ(National Olympic Committee, Moeys)។

➢ **ព្រឹត្តិការណ៍រៀបចំកីឡាអាស៊ីអាគ្នេយ៍ស៊ីហ្គេមលើកទី៣២**(Cambodia 2023) និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនិងទើបតែបានបញ្ចប់នាពេលថ្មីៗនេះដែរ។ ព្រឹត្តការណ៍ស៊ីហ្គេមធ្វើអោយប្រជាជនកម្ពុជាខ្លួនឯង ស្គាល់នូវការអភិវឌ្ឍ លទ្ធិប្រជាធិបតេយ្យ និងការស្រឡាញ់ជាតិ។ «ដូចដែលប្រជាពលរដ្ឋខ្មែររស់នៅសហរដ្ឋអាមេរិក ឬនៅក្រៅប្រទេសមួយចំនួនយល់ថា កម្ពុជាមានការអភិវឌ្ឍតិចតួច គ្មានកេរ្តិ៍ឈ្មោះល្អ គ្មានលទ្ធិប្រជាធិបតេយ្យជាដើម តាមរយៈការផ្សព្វផ្សាយអាក្រក់អំពីប្រទេសកម្ពុជា ប៉ុន្តែនៅពេលដែលឃើញព្រឹត្តិការណ៍ នេះធ្វើបានល្អ ពិភពលោកកោតស្ញប់ស្ញែង ហើយក៏មានបងប្អូនប្រជាពលរដ្ឋខ្មែរដែលស្នេហាជាតិ បានវិលពីបរទេសមកជួយធ្វើជាកីឡាករ ដើម្បីកេរ្តិ៍ឈ្មោះជាតិយើងទៀត ហើយនឹងធ្វើឱ្យការបង្អាប់កម្ពុជាលែងមាន»។ អ្នកជំនាញសេដ្ឋកិច្ច ក៏បានបញ្ជាក់ថា ស្ថិតនៅក្នុងរង្វង់៤ខែដើមឆ្នាំ២០២៣នេះ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា មាន ស្ថានភាពល្អជាងរយៈពេលដូចគ្នាកំឡុងឆ្នាំ២០២២ ឆ្នាំ២០២១ ឆ្នាំ២០២០ និងបើប្រៀបធៀបជាមួយនិងប្រទេសមួយចំនួននៅលើពិភពលោក សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នៅតែមានកំណើនល្អជាង ខណៈពេលពេលដែលប្រទេសទាំងនោះកំពុងតែជួបវិបត្តិ។ កម្ពុជាត្រូវបានប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងបណ្តាប្រទេសមួយចំនួននៅលើពិភពលោក វាយតម្លៃខ្ពស់ចំពោះការរៀបចំធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ចាប់ពីថ្ងៃទី៥ ដល់ទី ១៧ ខែឧសភា ឆ្នាំ២០២៣ ក្រោមពាក្យស្លោក «កីឡារស់ក្នុងសន្តិភាព»។ ក្នុងនោះកម្ពុជាបានប្រកាសមិនយកថ្លៃសំបុត្រចូលទស្សនាការប្រកួតនានា ផ្តល់ជូនការស្នាក់នៅហូបចុករបស់ប្រតិភូកីឡា និងមិនយកតម្លៃសេវាពីការលក់សិទ្ធិផ្សព្វផ្សាយពីគ្រប់ដៃគូរផ្សព្វផ្សាយនានា។ ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២នេះ មានកីឡាករ និងកីឡាការនី គ្រូបង្វឹក និងបុគ្គិលចូលរួម ជាង ១២ ៤០០ នាក់មកពីបណ្តាប្រទេសជាសមាជិកអាស៊ាន និងទីម័រខាងកើត។ ភ្នំពេញ – កីឡាស៊ីហ្គេម គឺជាទិវាកីឡាដ៏ធំ និងមានប្រជាប្រិយភាពរបស់ប្រជាជាតិក្នុងបណ្តាប្រទេសតំបន់អាស៊ីអាគ្នេយ៍ប្រារព្វឡើង ២ឆ្នាំម្តងតាមអក្ខរក្រម។ ទន្ទឹមគ្នានេះ នៅដើមខែឧសភា និងមិថុនាខាងមុខ កម្ពុជាទទួលបានឱកាសរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។ នេះជាលើកទីមួយហើយដែលកម្ពុជាមានសមត្ថភាពទទួលបានឱកាសរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដែលបានបង្ហាញពីសមត្ថភាពរបស់កម្ពុជា ព្រមទាំងជាឱកាសធ្វើឱ្យបរទេសស្គាល់ប្រទេសកម្ពុជាកាន់តែច្បាស់។ កម្ពុជាទទួលបានអត្ថប្រយោជន៍៤ ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដោយរួមមាន(ប្រសាសន៍លោកបណ្ឌិត ឈត ប៊ុនថង)៖

១. បង្ហាញពីសមត្ថភាពរៀបចំការប្រកួត និងទាក់ទាញវិនិយោគិន ៖ ការចូលរួមរបស់កម្ពុជាក្នុងការរៀបចំប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នឹងធ្វើឱ្យ

សាកលលោកមើលឃើញអំពីពីស្ថានភាពពិតរបស់ប្រទេសកម្ពុជា។ លើសពីនេះ បានចូលរួមទាក់ទាញវិនិយោគិនពីបរទេសចាប់អារម្មណ៍មកវិនិយោគនៅប្រទេសកម្ពុជា។

២. កេរ្តិ៍ឈ្មោះល្បីរន្ទឺនៅលើឆាកអន្តរជាតិ ៖ ការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ក៏ជាផ្នែកមួយដែលជួយឱ្យកម្ពុជាអាចទទួលបានមេដាយមាស មេដាយសំរិទ្ធ និងមេដាយប្រាក់ ជាពិសេសកេរ្តិ៍ឈ្មោះល្បីរន្ទឺនៅលើឆាកអន្តរជាតិ។ ក្នុងនោះ ការទទួលរៀបចំទីតាំងប្រកួតដែលមានការចូលរួមពីយុវជនស្ម័គ្រចិត្ត និងការស្វាគមន៍គណៈប្រតិភូកីឡាដ៏កក់ក្ដៅជាដើម ។ ម្យ៉ាងវិញទៀត កម្ពុជាក៏អាចបង្កើតវិញ្ញាសាប្រកួតដែលជារបស់ខ្មែរមកបញ្ចូលក្នុងការប្រកួតដែលសមស្របតាមគោលការណ៍នៃការប្រកួតបានផងដែរ។

៣. ផ្សព្វផ្សាយពីវប្បធម៌ខ្មែរ ៖ ការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ក៏ជាឱកាសដែលកម្ពុជាអាចបង្ហាញពីវប្បធម៌នៃការទំនាក់ទំនងក្នុងនាមជាម្ចាស់ផ្ទះ ការស្វាគមន៍ ព្រមទាំងមរតកវប្បធម៌ខ្មែរ ដូចជា របាំ ល្បុក្កតោ និងភារកិច្ចខ្មែរជាដើម។ លើសពីនេះ បើទោះជាកម្ពុជាសព្វថ្ងៃមិនទាន់ក្លាយជាប្រទេសអ្នកមានក៏ពិតមែន ប៉ុន្តែមានទឹកចិត្តធំទូលាយផ្ដល់ឱកាសឱ្យប្រតិភូកីឡា កីឡាករ កីឡាការិនី សាធារណៈជន បានចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ខាងមុខនេះ ដោយឥតគិតថ្លៃ។

៤. លើកកម្ពស់នយោបាយ សេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ៖ ផ្នែកនយោបាយកម្ពុជាព្យាយាមរក្សាសម្ព័ន្ធភាពល្អ មិនរើសអើងចំពោះប្រទេសជិតខាងលើបញ្ហានយោបាយ។ ទន្ទឹមគ្នានេះ កម្ពុជាកំពុងចង់បង្ហាញទៅកាន់ពិភពលោកថា កម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើជាម្ចាស់ផ្ទះប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។ ជាពិសេស បញ្ជាក់ថា កម្ពុជាមានសន្តិភាព និងសន្តិសុខនយោបាយ និងមានធនធានសមរម្យសម្រាប់ការរៀបចំការប្រកួត។

ប្រធានវិទ្យាស្ថានទំនាក់ទំនងវប្បធម៌ អប់រំ និងទេសចរណ៍ នៃរាជបណ្ឌិត្យសភាកម្ពុជា ក៏បានសំណូមពរដល់ ប្រជាពលរដ្ឋខ្មែរទាំងអស់ត្រូវមានមោទនភាពថាយើងអាចធ្វើបានក្នុងការរៀបចំព្រឹត្តិការណ៍ប្រកួតនេះ។ លើសពីនេះ សូមចូលរួមជាមួយអាជ្ញាធរ រក្សាសណ្ដាប់ធ្នាប់ គោរពច្បាប់ចរាចរណ៍។ ជាពិសេស ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ និងលើកទឹកចិត្តកីឡាករកម្ពុជា និងបរទេសឱ្យទទួលបានជោគជ័យ។

- ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាឧត្តមសិក្សានិងមធ្យមសិក្សាថ្នាក់ជាតិ ៖ គោលបំណងចម្បងនៃការប្រកួតនេះ គឺសំដៅដល់ប្រមូលផ្ដុំកីឡាករ កីឡាការិនី ដែល ជាមហាជនសិស្សានុសិស្ស ដែលស្រឡាញ់វិស័យកីឡាឱ្យមានឱកាសបានចូលរួមប្រកួត ប្រជែង ចែករំលែកបទពិសោធន៍ បង្កើនភាពសប្បាយរីករាយ ពង្រឹងកាយសម្បទាមាំមួន បង្កើនកម្លាំងបញ្ញាស្មារតីឈ្លាសវៃ និងជៀសផុតពីអំពើអសកម្មផ្សេងៗនៅក្នុងសង្គម។

### ៥.២.២.យុទ្ធសាស្ត្របញ្ហាកោណរបស់រាជរដ្ឋាភិបាល

ទិសដៅរួមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងនូវសង្គមកម្ពុជាមួយដែលរឹងមាំមាន សន្តិភាពស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរ ភាព និងសមធម៌ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិកាផ្សារ ភ្ជាប់ទៅនឹងគ្នានិងត្រូវបានពង្រឹងជានាថា ប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ និងមានសុខ ភាពល្អ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងរង្វង់គ្រួសារ និងក្នុងសង្គមជាតិ( Press OCM,2023 )។

## ៥.៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីធ្លាបៃតងសាធារណៈ សម្រាប់លើកកម្ពស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍

### ៥.៣.១.ហេដ្ឋារចនាសម្ព័ន្ធ

- ជំរុញ ស្តារ និងរៀបចំលម្ហសាធារណៈ ផ្ទៃបៃតង សួរសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យរួមមានកុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចំណាស់ និងជនពិការឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បង្គន់អនាម័យ និងបរិក្ខារ សម្រាប់សាធារណជន និងជនពិការដើម្បីធានាសោភ័ណភាពសាធារណៈ និងការធ្វើ ចរាចរណ៍ប្រកបដោយសុត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់សាធារណ ជន និងពិការ
- រៀបចំកែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិតមានអាទិ៍ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាប់ មណ្ឌលសុខភាព មន្ទីរពេទ្យ ឱសថស្ថាននៅក្នុងខណ្ឌស្របតាម បទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- រៀបចំឱ្យមានទីលានប្រណាំងរថយន្ត ទីធ្លាលម្ហែកាយ ចំណតនាវា ចំណតកាណូត ចំណតអូប័រ ចំណតទូកង និងពង្រីកព្រែកជីកដើម្បីនាវាអាចរាចរបានងាយស្រួល។

### ៥.៣.២.ទីធ្លាបៃតងសាធារណៈ

- កែច្នៃសួនច្បារលម្ហែកម្សាន្ត សួនកុមារ ទីលានសម្រាប់ប្រជាជនមកពីបណ្តាខេត្តឆ្ងាយៗមកកម្សាន្ត និងសេវាបម្រើវិស័យទេសចរណ៍ផ្សេងៗទៀត
- ជំរុញការរៀបចំអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ និងទេសចរណ៍កែច្នៃនៅតាមដងទន្លេ និងរុក្ខវិថី
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស និងការពារធនធានធម្មជាតិ និងជីវចម្រុះតាមដង ទន្លេមេគង្គ និងទន្លេសាប

- រៀចំដីចំណីច្រាំងទន្លេជាសួរច្បារ តំបន់លម្ហែកម្សាន្ត និងកន្លែងទេសចរណ៍ធម្មជាតិ ដែលមានអនាម័យបរិស្ថានល្អនិងរក្សាលក្ខណៈធម្មជាតិរបស់ទន្លេដើម្បីទាក់ទាញ ទេសចរកម្សាន្តតំបន់ក្បាលជ្រោយក្នុងសង្កាត់កោះដាច់ និងសង្កាត់ជ្រោយចង្វារបន្ថែម ទៀត
- រៀបចំកែលម្អ និងបំពាក់បន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធកីឡាតាមសួនច្បារសាធារណៈ

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់រាជរដ្ឋាភិបាលបានធានាជាប់ប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។ សម្រាប់ខណ្ឌជ្រោយចង្វារមានសក្តាសាធារណៈ គឺសំដៅរៀបចំ និងអភិវឌ្ឍខណ្ឌជ្រោយចង្វារជា"មជ្ឈមណ្ឌលទីក្រុងមាត់ទឹកនៃរាជធានីភ្នំពេញ ហ៊ុំព័ទ្ធដោយទន្លេសាប និងទន្លេមេគង្គលើដែលជាគោលដៅអភិវឌ្ឍប្រកបដោយសក្តានុពល ប្រកួតប្រជែងខ្ពស់និងទាក់ទាញបំផុតសម្រាប់លំនៅឋាន ពាណិជ្ជកម្ម សេដ្ឋកិច្ច ទេសចរណ៍ កសិកម្ម សិប្បកម្ម សេវាកម្ម និងវប្បធម៌ប្រកបដោយគុណភាពបរិស្ថានរស់នៅនិងប្រព័ន្ធចរាចរណ៍ល្អប្រសើរ"។

## ៥.៤-សន្និដ្ឋាន

ដើម្បីសម្រេចនូវគោលបំណង និងគោលដៅក្នុងការអនុវត្តផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីធ្លាបៃតងសាធារណៈដែលមានស្រាប់ និងថ្មីបន្ថែមទៀត សម្រាប់លើកកម្ពស់វិស័យកីឡា មានយុទ្ធសាស្ត្រសំខាន់ៗដែលចាំបាច់ក្នុងការរួមចំណែករួមមាននៅក្នុងយុទ្ធសាស្ត្របញ្ចកោណរាជរដ្ឋាភិបាលរួមមាន ( asset.cambodia.gov , cdc-crdb.gov )៖

➢ ការអភិវឌ្ឍលើក្របខណ្ឌច្បាប់និងយន្តការ
  - រៀបចំលិខិតបទដ្ឋាននិងយន្តការនានា ដើម្បីគាំទ្រនិងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព ដោយកំណត់ឱ្យមានកិច្ចសហការនិងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ
  - ធ្វើឱ្យប្រសើរឡើងនិងពន្លឿនការអនុវត្តគោលនយោបាយជាតិ ក្របខ័ណ្ឌច្បាប់យន្តការពាក់ព័ន្ធនានាដែលមានស្រាប់និងយន្តការថ្មីៗ
  - កសាងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងកម្មវិធីនានាដោយមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងក្រសួង ស្ថាប័នទទួលខុសត្រូវ។

➢ លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព
  - ជំរុញនិងលើកទឹកចិត្តយុវជនឱ្យទទួលបាននូវការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្រប ជាពិសេស យុវជន ដែលពុំសូវមានឱកាសនិងយុវជនដែលងាយរងគ្រោះ ក្នុងនោះយុវជនពិការ
  - ជំរុញកម្មវិធីបំណិនជីវិតដែលឆ្លើយតបទៅនឹងតម្រូវការដែលរស់នៅរបស់យុវជន និងទីផ្សារពលកម្ម

- ចូលរួមលើកកម្ពស់គុណភាពអប់រំផ្នែកបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងភាសាបរទេសនៅគ្រប់កម្រិតនៃប្រព័ន្ធ
- គ្រប់ភូមិសិក្សានៃប្រព័ន្ធនៃការអប់រំក្នុងប្រទេសកម្ពុជាដើម្បីឱ្យស្របតាមតម្រូវការរបស់សង្គមជាតិ និងស្របតាមស្តង់ដាតំបន់និងអន្តរជាតិ។
- បង្កឱកាសដល់យុវជនកម្ពុជាទាំងអស់ឱ្យទទួលបាននិងបញ្ចប់ការសិក្សាយ៉ាងហោចណាស់ត្រឹមការអប់រំកម្រិតមូលដ្ឋាន និងបង្កើនអត្រាគង់វង្សនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំ
- អភិវឌ្ឍមជ្ឈមណ្ឌលយុវជននិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំរុញលើកទឹកចិត្តយុវជនឱ្យចូលរួមយ៉ាងសកម្មក្នុងការសិក្សានិងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមសហគមន៍ខ្លួន
- រៀបចំកែលម្អ និងបំពាក់បន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធកីឡាតាមសួនច្បារសាធារណៈ
- បង្កើនទីលានហាត់ប្រាណទាំងសាធារណៈ និងឯកជន

# ជំពូកទី៦

# សេចក្តីសន្និដ្ឋាននិងអនុសាសន៍

## សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះគឺបង្ហាញលទ្ធផលដែលបានរកឃើញជាលើកចុងក្រោយ។ អាស្រ័យហេតុនេះ ជំពូកនេះត្រូវបែងចែកជាបួនផ្នែក៖ ផ្នែកទី១ សង្ខេបពីលទ្ធផលដែលបានវិភាគទិន្នន័យក្នុងជំពូកទី៤ ផ្នែកទី២ សេចក្តីសន្និដ្ឋាន ផ្នែកទី៣ ការលើកកម្ពស់និងការផ្តល់អនុសាសន៍ និងផ្នែកចុងក្រោយការស្រាវជ្រាវនាថ្ងៃអនាគត។

## ៦.១.សេចក្តីសង្ខេប

យោងតាមលទ្ធផលនៃការវិភាគទិន្នន័យ បានបង្ហាញថាលទ្ធផលមធ្យមមេគុណរបស់ អថេរទាំងប្រាំរួមមាន ការយល់ដឹងរបស់ប្រជាពលរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធកីឡា ភាសាសកលនៃវិស័យកីឡា ទីផ្សារកីឡា និង ទីធ្លាបៃតងសាធារណៈនិងសុខុមាលភាព នៅក្នុងខណ្ឌជ្រោយចង្វារ មានទំនោរខិតទៅរកកម្រិតភាពពេញចិត្ត។ ចំណែកឯលទ្ធផលនៃរីហ្គ្រេសិនបានរកឃើញថាអថេរឯករាជ្យទាំង៤ សុទ្ធតែមានទំនាក់ទំនងជាមួយអថេរពឹងផ្អែកនូវកម្រិត៥% និង១%។ ដូច្នេះសម្មតិកម្មសូន្យទាំង៤ ត្រូវបានតេស្តដូចខាងក្រោមនេះ៖

**សម្មតិកម្មសូន្យទី១(Ho1)៖**”ការយល់ដឹងរបស់ប្រជាពលរដ្ឋមិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ” ត្រូវបដិសេធ។

**សម្មតិកម្មសូន្យទី២(Ho2)៖** ”ហេដ្ឋារចនាសម្ព័ន្ធកីឡាមិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ” ត្រូវបដិសេធ។

**សម្មតិកម្មសូន្យទី៣(Ho3)៖** ”ភាសាសកលនៃវិស័យកីឡាមិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ” ត្រូវបដិសេធ។

**សម្មតិកម្មសូន្យទី៤(Ho4)៖** ”ទីផ្សារកីឡាមិនមានលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាពនៃការអភិវឌ្ឍសហគមន៍ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ” ត្រូវបដិសេធ។

## ៦.២.សេចក្តីសន្និដ្ឋាន

សរុបមកផ្អែកលើលទ្ធផលខាងលើ អថេរនៃសូចនាករនៃការចូលរួមរបស់វិស័យកីឡារួមមាន៖ ការយល់ដឹងរបស់ប្រជាពលរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធកីឡា ភាសាសកលនៃវិស័យកីឡា និងទីផ្សារ

កីឡា និង សុទ្ធតែលើកកម្ពស់ទីធ្លាបៃតងសាធារណៈនិងសុខុមាលភាព របស់ខណ្ឌជ្រោយចង្វារ។ ដូច្នេះការសិក្សានេះអាចវាយតម្លៃបានថា ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងខណ្ឌជ្រោយចង្វារ មានភាពពេញចិត្តខ្លាំងចំពោះហេដ្ឋានរចនាសម្ព័ន្ធកីឡា និងចូលរួមសហការជាមួយប្រជាពលរដ្ឋ និងបានចូលរួមចំណែកយ៉ាងសកម្មធ្វើឱ្យសកម្មភាពប្រចាំថ្ងៃ សកម្មភាពផ្សព្វផ្សាយនិងមតិចូលរួមរបស់អ្នកផ្តល់ទិន្នន័យមានឥទ្ធិពលយ៉ាងសំខាន់ទៅលើការលើកកម្ពស់ទីធ្លាបៃតងសាធារណៈនិងសុខុមាល-ភាពនៃវិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍។ ក្នុងករណីនេះបានបញ្ជាក់ថាវិស័យកីឡាពិតជាមានសារៈសំខាន់និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសហគមន៍និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

## ៦.៣.លទ្ធផលនិងអនុសាសន៍

យោងតាមលទ្ធផលនៃការស្រាវជ្រាវនេះបានឃើញពីការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍។ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមខាងលើនេះអ្នកស្រាវជ្រាវសូមលើកយកនូវគំនិតយោបល់និងសំណូមពរដល់ភាគីពាក់ព័ន្ធដូចតទៅ៖ តាមរយៈ ក្រសួងអប់រំ យុវជន និងកីឡា (គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា២០១៥)

- ប្តេជ្ញាចិត្តក្នុងការពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពវិទ្យាស្ថានអប់រំកាយនិងកីឡា និងមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា
- លើកកម្ពស់សមត្ថភាពអង្គការសង្គមកីឡារួមមានសហព័ន្ធកីឡាជាតិគ្រប់ប្រភេទ
- ជំរុញការអប់រំ បណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សឱ្យមានគុណភាព
- ធានាពង្រឹងកិច្ចសហការដោយធានាឱ្យមានតំណាងរាជរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី
- ពង្រឹងសន្តិភាព មិត្តភាព និងគោរពគ្នាទៅវិញទៅមកតាមរយៈសកម្មភាពអប់រំកាយ និងកីឡាដើម្បីរួមវិភាគទានបង្កបរិយាកាសដោះស្រាយបញ្ហាអន្តរជាតិ
- លើកកម្ពស់ការធ្វើវិនិយោគលើវិស័យអប់រំកាយនិងកីឡា
- លើកកម្ពស់ចលនទូបត្ថម្ភនិងសិទ្ធិភ្នាក់ងារផ្សព្វផ្សាយព្រឹត្តិការណ៍កីឡា
- អនុវត្តផែនការសកម្មភាពកីឡានៅក្នុងសហគមន៍វប្បធម៌អាស៊ាន។

## ៦.៤.ដែនកំណត់និងការស្រាវជ្រាវនាពេលអនាគត

ដោយផ្អែកលើដែនកំណត់នៃការសិក្សាបច្ចុប្បន្នដូចបានរៀបរាប់ក្នុងជំពូកទី១ វិសាលភាពសម្រាប់ការស្រាវជ្រាវបន្ថែមត្រូវបានបង្ហាញដូចខាងក្រោម៖

១.ការស្វែងយល់ពីការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍន៍សហគមន៍ដែលស្ថិតនៅក្នុងតំបន់ដែលទទួលផលពីវិស័យកីឡា តាមរយៈការធ្វើសម្រង់មតិជាមួយប្រជាពលរដ្ឋដែលស្ថិតនៅតំបន់ដែលកំពុងទទួលផល។

២.ដើម្បីពិនិត្យអំពីលទ្ធផលកម្រិតនៃការចូលរួមនិងការបញ្ចេញទស្សនៈរបស់ប្រជាពលរដ្ឋអ្នកពាក់ព័ន្ធលើអថេរឯករាជ្យដូចជា អត្ថប្រយោជន៍ និងសារៈសំខាន់នៃវិស័យកីឡា គោលបំណងនៃការពង្រឹងដំណើរការនៃការរៀបចំផែនការអនុវត្ត កត្តាចាំបាច់ដែលជាយន្តការពាក់ព័ន្ធ

៣.សម្រាប់សិស្ស និស្សិត ឬអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ នាពេលអនាគតអាចពិចារណាទៅលើផ្នែកផ្សេងៗបន្ថែមទៀត រួមទាំងកត្តាពាក់ព័ន្ធដទៃផ្សេងៗទៀតដែលបានចូលរួមជាមួយវិស័យកីឡាដើម្បីជាប្រយោជន៍ដ៏កំណើនអភិវឌ្ឍសហគមន៍។ ដូចច្នេះដែនកំណត់នៃការសិក្សាស្រាវជ្រាវក្នុងពេលបច្ចុប្បន្នគឺបានផ្ដល់ជាធាតុចូលលើចំណុចរួមផ្សំដែលជាសកម្មភាព និងជាបេសកម្មមួយដែលជាផ្នែកពាក់ព័ន្ធចាំបាច់លើការចូលរួមរបស់វិស័យកីឡាថាពិតជាបានបង្កឱ្យសហ-គមន៍មានការអភិវឌ្ឍយ៉ាងពិតប្រាកដ។

សរុបមក ការសិក្សាស្រាវជ្រាវបច្ចុប្បន្នបានព្យាយាមវិភាគទិន្នន័យដោយប្រើទំហំសំណាកបន្ថែមទៀត និងវាយតម្លៃប្រសិទ្ធភាពព្រមទាំងគុណតម្លៃនៃការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍជីវភាពសហគមន៍។ ចលនាកីឡាជាផ្នែកមួយដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ កីឡាបានជះឥទ្ធិពលគ្រប់ទីកន្លែងជុំវិញពិភពលោកមិនថានៅក្នុងប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍឬប្រទេសក្រោមការអភិវឌ្ឍនោះឡើយ ដែលកីឡាតែងតែជាឱសថក្នុងការបង្កភាពសប្បាយរីករាយ មោទនភាពជាតិ សាមគ្គីភាព មិត្តភាព សន្តិភាពនិងឧត្តមភាពជាតិលើឆាកអន្តរជាតិ ពីសកម្មភាពកីឡានិងព្រឹត្តិការណ៍កីឡានានា (គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា)។

ទន្ទឹមនឹងនេះផងដែរកម្ពុជាធ្លាប់ឆ្លងកាត់សោកនាដកម្មនៃសង្គ្រាមដែលធ្វើឱ្យវិស័យកីឡាក៏ដូចជាវិស័យដ៏ទៃទៀតធ្លាក់ចុះក្រោមសូន្យ ហើយតាមរយៈពន្លឺនៃ**សន្តិភាព** ស្ថេរភាពនយោបាយកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម៧.៧% ក្នុងរយៈពេលពីទស្សវត្សចុងក្រោយ វិស័យកីឡានៅកម្ពុជា បានរីកចម្រើននិងទទួលបានការគាំទ្រពីយុវជននិងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។ ក្នុងបរិការណ៍ប្រជាសាស្ត្រសម្បូរដោយប្រជាពលរដ្ឋវ័យក្មេងជាក្ដីសង្ឃឹមនៃកម្លាំងការងារ ជាអនាគតរឹងមាំនៃប្រទេសជាតិ។ កីឡាជាមោទនភាពជាតិ ជាឧត្តមភាពជាតិ និងជាចំណីអាហារបំប៉នថាមពលរាងកាយនិងជាចំណីអារម្មណ៍ ដែលមិនអាចខ្វះបានក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ( Press OCM )។

បច្ចុប្បន្ននេះកីឡាក្លាយជាចលករអភិវឌ្ឍសង្គមក្លាយជាឧស្សាហកម្មកីឡា ធុរកិច្ចកីឡានិងជានយោបាយទ្រទ្រង់សង្គមទាំងក្នុងនិងក្រៅប្រទេស ពិសេសកីឡាក្លាយជាចលនាទ្រទ្រង់សេវាសុខភាពសាធារណៈដ៏មានប្រសិទ្ធភាព ដែលរាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្ពស់ក្នុងការក្នុងការរៀបចំនិងការដាក់ចេញនូវគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍអប់រំកាយនិងកីឡាដើម្បីជាកត្តាកំណត់ចក្ខុវិស័យជាតិប្រកបដោយសក្ដានុពលនិងឧត្តមភាពជាតិក្នុងតំបន់និងក្នុងពិភពលោក( ប្រសាសន៍សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងឱកាសពីធីបិទកីឡាជាតិលើកទី៣ ២១/១១/២០២២ )។

# ឯកសារយោង


1. https://asset.cambodia.gov.kh/mlmupc/wp-content/uploads/2023/11/2-%E1%9E%94%E1%9F%92%E1%9E%9B%E1%9E%84%E1%9F%8B%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%BE%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%9F%E1%9F%8B%E1%9E%8A%E1%9E%B8%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%87%E1%9F%92%E1%9E%9A%E1%9F%84%E1%9E%99%E1%9E%85%E1%9E%84%E1%9F%92%E1%9E%9C%E1%9E%B6%E1%9E%9A_with_QR_code.pdf
2. Chivorn. (2024, July 11). សម្តេចធិបតី ហ៊ុន ម៉ាណែត៖ វិស័យកីឡាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និង បានដើរតួនាទីយ៉ាងសំខាន់ ទាំងនៅកម្ពុជា និង សកលលោក, ដោយកីឡាទទួលបានការចាប់អារម្មណ៍ និង គាំទ្រ កាន់តែច្រើនពីសំណាក់មហាជន. FRESHNEWS
3. Cambodia 2023ផែនការមេឆ្ពោះទៅកាន់ការធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games)លើកទី៣២ ឆ្នាំ២០២៣ (២០១៦-២០២៣) បានទទួលការ

   ឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦
4. De Burca, J. (2023, August 18). ទីក្រុងសម្រាប់សុខុមាលភាព៖ យុគសម័យថ្មីនៃការអភិវឌ្ឍន៍ទីក្រុងក្រោយកំណើន. Constructive Voices.
5. Home -Global S4D Community https://community.sport-for-development.com/p/36
6. https://www.anocolympic.org/nocs-directory/national-olympic-committee-of-cambodia/16209
7. https://a4hsports.ca/benefits-of-youth-sports-on-the-community-creating-an-ecosystem/
8. https://constructive-voices.com/km/%E1%9E%80%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%9A%E1%9E%85%E1%9E%93%E1%9E%B6%E2%80%8B%E1%9E%

80%E1%9E%93%E1%9F%92%E1%9E%9B%E1%9F%82%E1%9E%84%E2%80%8B%E1%9E%94%E1%9F%83%E1%9E%8F%E1%9E%84%E2%80%8B%E1%9E%85%E1%9E%98%E1%9F%92%E1%9E%9A%E1%9E%BB%E1%9F%87%E2%80%8B%E1%9E%80%E1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E2%80%8B%E1%9E%80%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%92%E1%9F%92%E1%9E%9C%E1%9E%BE%E2%80%8B%E1%9E%95%E1%9F%82%E1%9E%93%E1%9E%80%E1%9E%B6%E1%9E%9A%E2%80%8B%E1%9E%91%E1%9E%B8%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%BB%E1%9E%84%E2%80%8B%E1%9E%91%E1%9F%86%E1%9E%93%E1%9E%BE%E1%9E%94/

9. https://community.sport-for-development.com/
10. https://education.ams.com.kh/education-update/national/news/dr-chhit-bunthong-cambodia-has-four-benefits-from-hosting-the-sea-games
11. https://education.ams.com.kh/education-update/national/news/dr-chhit-bunthong-cambodia-has-four-benefits-from-hosting-the-sea-games
12. https://m.freshnewsasia.com/index.php/en/localnews/348267-2024-07-11-12-57-14.html
13. https://www.information.gov.kh/articles/94434
14. https://www.nationthailand.com/category/news/sport
15. https://olympics.com/en/
16. KH_Development_Cooperation_and_Partnerships_Strategy_DCPS_2024_2028.pdf
17. https://www.ocm.gov.kh/pentagonal-strategy/
18. National Olympic Committee of Cambodia

➢ https://olympics.com/ioc/cambodia

របាយកាណ៍បូកសរុបសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ ២០២២-២០២៣និងសិក្ខាសាលាថ្នាក់ជាតិស្តីពីអភិបាលកិច្ចល្អនៃការគ្រប់គ្រង ព្រឹត្តិការណ៍កីឡា( លិខិតលេខ០០៤/២២ រ.ប.ក )

19. Press OCM. ( 2022, July 11 ). https://pressocm.gov.kh/archives/75048

20. ក្រសួងអប់រំ យុវជន និងកីឡា( Moeys )

- ឯកសារពាក់ព័ន្ធនិងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានកីឡា
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យកីឡា
- https://community.sport-for-development.com/p/36

# តារាងឧបសម្ព័ន្ធ

## កម្រងសំណួរស្រាវជ្រាវ

## ស្តីអំពីការសិក្សាលើករណី

## ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ក្នុងរាជធានីភ្នំពេញ

សូមគោរពជម្រាបសួរ លោក លោកស្រី អ្នកនាង កញ្ញា និងសិស្សនិស្សិត ជាទីគោរព និងជាទីស្រលាញ់រាបអាន នាងខ្ញុំជា និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញ គ្រប់គ្រងពាណិជ្ជកម្ម (MBA) នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ នៅក្នុងថ្ងៃនេះនាងខ្ញុំសូមធ្វើការអនុញ្ញាតពី លោក លោកស្រី អ្នកនាង កញ្ញា និងសិស្សនិស្សិត ដើម្បីចំណាយពេលដ៏មានតម្លៃក្នុងការឆ្លើយនូវកម្រងសំណួរ ទាក់ទងនឹង ការចូលរួមរបស់វិស័យកីឡាក្នុងការអភិវឌ្ឍសហគមន៍ក្នុងរាជធានីភ្នំពេញ ក្នុងគោលបំណងដើម្បីចងក្រងជារបាយការណ៍ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

ជាចុងក្រោយនាងខ្ញុំ សូមគោរពអរគុណចំពោះការចូលរួមរបស់ លោក លោកស្រី អ្នកនាង កញ្ញា និងសិស្ស និស្សិត។ នាងខ្ញុំសូមធានាថា រាល់ចម្លើយរបស់អស់លោក លោកស្រី អ្នកនាង កញ្ញា និងសិស្សនិស្សិត នឹងត្រូវបានរក្សាទុកជាការសម្ងាត់។

### ផ្នែក I ៖ ព័ត៌មានទូទៅ

សូមឆ្លើយសំណួរខាងក្រោមអំពីខ្លួនអ្នក។

**ក. ភេទ**

☐ ១) បុរស

☐ ២) ស្រី

☐ ៣) ផ្សេងទៀត (សូមបញ្ជាក់)

**ខ. អាយុ**

☐ ១) ១៨-២៤

☐ ២) ២៥-៣៤

☐ ៣) ៣៥-៤៤

☐ ៤) ៤៥-៥៤

☐ ៥) ៥៥ ឬខ្ពស់ជាងនេះ

**គ. កម្រិតនៃការអប់រំ**

☐ ១) បឋមសិក្សា

☐ ២) អនុវិទ្យាល័យ

☐ ៣) វិទ្យាល័យ

☐ ៤) បរិញ្ញាបត្រ

☐ ៥) បរិញ្ញាបត្រជាន់ខ្ពស់

☐ ៦) ផ្សេងទៀត (សូមបញ្ជាក់)

**ឃ. មុខរបរបច្ចុប្បន្ន**

☐ ១) សិស្សនិស្សិត

☐ ២) បុគ្គលិកស្ថាប័ន ឬក្រុមហ៊ុន

☐ ៣) ម្ចាស់អាជីវកម្ម

☐ ៤) ចូលនិវត្តន៍

☐ ៥) ផ្សេងទៀត (សូមបញ្ជាក់)

**ង. តើប្រព័ន្ធផ្សព្វផ្សាយសង្គមមួយណាដែលអ្នកប្រើញឹកញាប់ជាងគេ?**

☐ ១) Facebook

☐ ២) Instagram

☐ ៣) Twitter

☐ ៤) TikTok

☐ ៥) Telegram

☐ ៦) LinkedIn

☐ ៧) ផ្សេងទៀត (សូមបញ្ជាក់)

**ឆ. តើឧបករណ៍ចល័តណាខ្លះដែលអ្នកចូលប្រើញឹកញាប់បំផុត?**

១) ស្មាតហ្វូន

២) កុំព្យូទ័រ / កុំព្យូទ័រយួរដៃ

៣) ផ្សេងទៀត (សូមបញ្ជាក់)

**ឆ. តើឧបករណ៍ចល័តណាខ្លះដែលអ្នកចូលប្រើញឹកញាប់បំផុត?**

១) ស្មាតហ្វូន

២) កុំព្យូទ័រ / កុំព្យូទ័រយួរដៃ

៣) ផ្សេងទៀត (សូមបញ្ជាក់)

## ផ្នែកទី II៖ វិស័យកីឡា

សូមឆ្លើយសំណួរខាងក្រោមអំពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អ្នកសម្រាប់ព័ត៌មាន និងការគាំទ្ររបស់ប្រជាពលរដ្ឋក្នុងសហគមន៍

១=មិនពេញចិត្តខ្លាំង, ២=មិនពេញចិត្ត, ៣=អាចទទួលយកបាន, ៤=ពេញចិត្ត, ៥=ពេញចិត្តខ្លាំង

១. ការយល់ដឹងរបស់ប្រជាពលរដ្ឋ(IV1)

| **សេចក្តីអធិប្បាយ** | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| តើអ្នកចូលចិត្តលេងកីឡាឬទេ? | | | | | |
| តើអ្នកគិតថាអ្នកបានទទួលអត្ថប្រយោជន៍អ្វីខ្លះពីវិស័យកីឡាផ្សេងៗគ្នា និងផ្តល់ឱកាសឱ្យកុមារក្នុងការបង្កើនសមត្ថភាពសង្គម និងពង្រីកបណ្តាញទំនាក់ទំនង | | | | | |
| កីឡាបានដើរតួនាទីសំខាន់យ៉ាងណាខ្លះចំពោះការលើកកម្ពស់មុខមាត់ប្រទេសជាតិ លើឆាកជាតិនិងអន្តរជាតិ | | | | | |

២. ហេដ្ឋារចនាសម្ព័ន្ធកីឡា (IV2)

| សេចក្តីអធិប្បាយ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| ការបង្កើតឱ្យមានទីធ្លាកីឡាតាមទីសាធារណៈផ្តល់ឱ្យមានភាពសុខុដុមរមនាចំពោះសុខភាព? | | | | | |
| ការរៀបចំនូវព្រឹត្តិការណ៍កីឡាធំៗជាយន្តការមួយដែលធ្វើឱ្យប្រទេសជាតិមានសក្តានុពល និងលើកមុខមាត់ប្រទេសជាតិ | | | | | |
| ការរីកចម្រើននៃកីឡាជាកត្តាជំរុញទំនាក់ទំនងរវាងប្រទេសនិងប្រទេស | | | | | |
| ការរស់នៅមានភាពសុខុដុមនិងមានសាមគ្គីភាព | | | | | |

៣. ភាសាសាកលនៃវិស័យកីឡា(IV3)

| សេចក្តីអធិប្បាយ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| ការលេងកីឡាជាការបង្ហាញពីសាមគ្គីភាពសង្គម ប្រកបដោយសុខុមរមនា ក្រោមម្លប់សន្តិភាព | | | | | |
| កសាងវប្បធម៌កីឡាដើម្បីគាំទ្រគោលនយោបាយភូមិឃុំមានសុវត្ថិភាព | | | | | |
| លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងសកម្មភាពកីឡាដើម្បីចូលរួមចំណែកអភិវឌ្ឍផ្នែកសុខភាពរាងកាយ បញ្ញា និងស្មារតីរបស់ប្រជាពលរដ្ឋ | | | | | |

៤.ទីផ្សារកីឡា (IV4)

| សេចក្ដីអធិប្បាយ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| គួរជំរុញការនាំចូលផលិតផលកីឡាឱ្យមានភាពទូលំទូលាយ និងមានតម្លៃសមរម្យ | | | | | |
| ជំរុញការផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃកីឡាឱ្យបានទូលំទូលាយ | | | | | |
| បង្កើនការរៀបចំសកម្មភាពកីឡាតាមរយៈការប្រកួតនៅតាមសាលារៀន និងតាមបណ្ដាលខេត្តផ្សេងៗ | | | | | |
| បង្កើនលទ្ធភាពក្នុងការរៀបចំព្រឹត្តិការណ៍កីឡាធំជាលក្ខណៈជាតិនិងអន្តរជាតិ | | | | | |
| ជំរុញនិងផ្ដល់ការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារសំខាន់ចំពោះសុខភាពតាមរយៈការលេងកីឡា | | | | | |

## ផ្នែកទីIII៖ ទីធ្លាបៃតងសាធារណៈ និងសុខុមាលភាព

សូមឆ្លើយសំណួរខាងក្រោមអំពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អ្នកសម្រាប់ព័ត៌មាន និងការគាំទ្ររបស់ប្រជាពលរដ្ឋក្នុងសហគមន៍

១=មិនពេញចិត្តខ្លាំង, ២=មិនពេញចិត្ត, ៣=អាចទទួលយកបាន, ៤=ពេញចិត្ត, ៥=ពេញចិត្តខ្លាំង

| សេចក្ដីអធិប្បាយ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| តើនៅតំបន់ដែលអ្នករស់នៅមានទីកន្លែងកីឡាសាធារណៈដែលល្អប្រសើរដែរឬទេ ? | | | | | |
| តើអ្នកយល់ថាការបង្កើតហេដ្ឋារចនាសម្ព័ន្ធកីឡាពិតផ្ដល់អត្ថប្រយោជន៍សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋមែនឬទេ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ការមានទីតាំងកីឡានៅទីសាធារណៈពិតជាបង្កើននូវសហគមន៍មួយដែលមានភាពសុខុមដុមមែនឬទេ ? | | | | | |
| ការបង្កើតសួនកីឡានៅតាមទីសាធារណៈផ្តល់នូវភាពវិជ្ជលើផ្នែកសុខមាលភាពជូនដល់ប្រជាពលរដ្ឋមែនឬទេ ? | | | | | |